សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការសុំកូន និងសិទ្ធិរបស់កូនសុំ នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ខេង ឌួចលាង**

សាស្ត្រាចារ្យណែនាំ
លោក **ម៉ៅ មុន្នីណា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី១៩

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ខេង ឌួចលាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៩ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៨-២០១៩ សូមគោរពសម្តែងកតញ្ញូតាធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក ហ៊ិន សុខខេង និង អ្នកម្តាយ ចិត្រ សុភាព** ដែលជាអ្នកមានគុណ បានផ្តល់កំណើតឱ្យកូន ផ្តល់ក្តីស្រលាញ់ និងការថែទាំ ផ្តល់ចំណេះដឹង និងដំបូន្មានល្អៗដល់កូន។ លោកទាំងពីរបានផ្តល់ការលើកទឹកចិត្ត និងជ្រោមជ្រែងគ្រប់ស្ថានភាពទាំងអស់ និងបានឧបត្ថម្ភផ្នែកថវិកា ដើម្បីឲឱ្យនាងខ្ញុំទទួលបានការអប់រំ តាំងពីក្មេងរហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** សាកលវិទ្យាធិការ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច  ដែលបានអនុញ្ញាតឱ្យនាងខ្ញុំបានចូលសិក្សា និងក្លាយជានិស្សិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យនេះ និងបានផ្តល់ភាពងាយស្រួលដល់ការសិក្សារបស់នាងខ្ញុំ។

**លោកសាស្ត្រាចារ្យ ម៉ៅ មុណ្ណា** ជាសាស្ត្រាចារ្យណែនាំដ៏ល្អមួយរូប ដែលបានខិតខំប្រឹងប្រែងនិងចំណាយពេលវេលាក្នុងការបង្ហាត់បង្រៀន ពន្យល់បន្ថែម និងផ្តល់ជាយោបល់ ប្រភពឯកសារនានាដល់នាងខ្ញុំ ដើម្បីជាទុនក្នុងការចងក្រងសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

**លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យគ្រប់មុខវិជ្ជាទាំងអស់ផ្នែកនីតិសាស្ត្រ** នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងពន្យល់ណែនាំ និងផ្ទេរចំណេះដឹងព្រមទាំងបទពិសោធន៍ជាច្រើនដល់និស្សិតគ្រប់ៗរូប ។

មិត្តនិស្សិតទាំងអស់ ដែលបានផ្តល់ជាយោបល់ និងឯកសារនានាជាជំនួយដល់ការសរសេរសារណានេះ។ ឯកសារទាំងអស់ពិតជាមានសារៈប្រយោជន៍ជាខ្លាំងសម្រាប់ការស្រាវជ្រាវរបស់នាងខ្ញុំ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធិពរជ័យសិរីបវរជូន **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាស្ត្រាចារ្យណែនាំ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិត** ទាំងអស់ឱ្យជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

កុមារ គឺជាទំពាំងដែលនឹងស្នងឬស្សីនៅថ្ងៃអនាគត។ កិច្ចការពារផលប្រយោជន៍កុមារ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបនៅក្នុងសង្គម។ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ពិតជាបានខ្វាយខ្វល់ពីសិទ្ធិរបស់ប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសគឺស្ត្រី និងកុមារ។ យើងត្រូវតែធានាថាកុមារគ្រប់រូបអាចទទួលបានសិទ្ធិគ្រប់យ៉ាង ដើម្បីការរីកចំរើន និងការអភិវឌ្ឍខ្លួន នៅក្នុងគ្រួសារមួយដែលល្អ ប្រកបដោយភាពកក់ក្ដៅ និងគ្មានការបំពាន។ ផ្ទុយទៅវិញ បើកុមារនោះរស់នៅក្នុងគ្រួសារដែលមិនល្អ មិនមានការមើលថែពីឪពុកម្ដាយ ឬទទួលរងអំពើហិង្សាទៀតនោះ វានឹងធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ និងសិទ្ធិរបស់កុមារ ដែលជាកត្តាធ្វើឲ្យមានការប៉ះពាល់ដល់ការរីកចំរើនធំធាត់របស់កុមារទៀតផង។

ដូច្នេះទើបនាងខ្ញុំលើកយកប្រធានបទមួយស្ដីពី «**ការសុំកូន និងសិទ្ធិរបស់កូនសុំនៅព្រះរាជាណាចក្រកម្ពុជា**» ដែលជាបញ្ហាគួរឱ្យកត់សម្គាល់ផងដែរ ព្រោះថាប្រជាពលរដ្ឋមួយចំនួននៅពុំទាន់យល់ពីការសុំកូននៅប្រទេសយើងនៅឡើយ។ ច្បាប់ដែលមានចែងពីការសុំកូនពិតជាមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងការធានាផលប្រយោជន៍ និងសិទ្ធិកុមារ ដូច្នេះយើងគួរគប្បីសិក្សាស្វែងយល់ឱ្យបានលម្អិត។

នាងខ្ញុំ រួមជាមួយសាស្ត្រាចារ្យណែនាំ បានប្រឹងប្រែងអស់ពីលទ្ធភាព ក្នុងការស្រាវជ្រាវ និងចងក្រងសរសេរអត្ថបទសារណានេះឲ្យបានល្អបំផុត។ នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា តាមរយៈការសិក្សា និងបកស្រាយប្រធានបទនេះ នឹងស្រាយចម្ងល់ បានជាប្រយោជន៍ដល់បងប្អូននិស្សិត ក៏ដូចជាប្រជាពលរដ្ឋទាំងអស់។ ជាមួយគ្នានេះដែរ នាងខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គង ចំណុចត្រង់ណាដែលនាងខ្ញុំធ្វើការស្រាវជ្រាវមានភាពខ្វះចន្លោះ ឬមិនទាន់គ្រប់គ្រាន់ និងកំហុសអក្ខរាវិរុទ្ធនានា ដែលកើតមានឡើងដោយអចេតនា។

ជាចុងក្រោយ នាងខ្ញុំសូមជូនពរដល់សាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់រូបឱ្យមានសុខភាពល្អ និងសំណាងល្អ។ សូមអរគុណ ចំពោះការចំណាយពេលវេលាយកចិត្តទុកដាក់លើសារណារបស់នាងខ្ញុំ។

# <u>មាតិកា</u>

**ទំព័រ**

**សេចក្តីផ្តើម** ............ ១

## ជំពូកទី១
## លក្ខខណ្ឌ និងអានុភាពនៃការសុំកូន

**ផ្នែកទី១ ៖ សុំកូនពេញលេញ** ............ ៥

**កថាខណ្ឌទី១ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ** ............ ៥

ក. លក្ខខណ្ឌគ្រឹះ ............ ៥

ក.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ............ ៦

ក.២. លក្ខខណ្ឌចំពោះកូនសុំ ............ ៨

ក.៣. លក្ខខណ្ឌផ្សេងៗទៀត ............ ១០

ខ. លក្ខខណ្ឌទម្រង់ ............ ១១

ខ.១. ការដាក់ពាក្យ និងអ្នកដែលមានសិទ្ធិដាក់ពាក្យសុំ ............ ១១

ខ.២. ទម្រង់នៃពាក្យសុំ ............ ១២

ខ.៣. ស្ថាប័នទទួលពាក្យសុំ ............ ១២

**កថាខណ្ឌទី២ ៖ អានុភាពនៃសុំកូនពេញលេញ** ............ ១៣

ក. ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម ............ ១៣

ខ. ការផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ............ ១៣

**ផ្នែកទី២ ៖ សុំកូនធម្មតា** ............ ១៥

**កថាខណ្ឌទី១ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា** ............ ១៥

ក. លក្ខខណ្ឌគ្រឹះ ............ ១៥

ក.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ............ ១៥

ក.២. លក្ខខណ្ឌចំពោះកូនសុំធម្មតា ............ ១៧

ក.៣. លក្ខខណ្ឌផ្សេងៗទៀត ............ ១៧

ខ. លក្ខខណ្ឌទម្រង់ ............ ១៨

ខ.១. ការដាក់ពាក្យ និងអ្នកមានសិទ្ធិដាក់ពាក្យសុំ ............ ១៨

ខ.២. ទម្រង់នៃពាក្យសុំ ............ ១៩

ខ.៣. ស្ថាប័នទទួលពាក្យសុំ ............ ១៩

**កថាខណ្ឌទី២ ៖ អានុភាពនៃសុំកូនធម្មតា** ........ ១៩

ក. ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម ........ ១៩

ខ. ការបន្តញាតិភាពជាមួយឪពុកម្ដាយបង្កើត ........ ២០

## ជំពូកទី២

## ការកាត់កាល់សុំកូន

**ផ្នែកទី១ ៖ ការកាត់កាល់សុំកូនពេញលេញ** ........ ២១

**កថាខណ្ឌទី១ ៖ មូលហេតុនៃការកាត់កាល់** ........ ២១

**កថាខណ្ឌទី២ ៖ អ្នកមានសិទ្ធិកាត់កាល់** ........ ២២

ក. កូនសុំ ........ ២២

ខ. ឪពុកម្ដាយបង្កើត ........ ២២

គ. តំណាងអយ្យការ ........ ២៣

**កថាខណ្ឌទី៣ ៖ អានុភាពនៃការកាត់កាល់សុំកូនពេញលេញ** ........ ២៣

**ផ្នែកទី២ ៖ ការកាត់កាល់សុំកូនធម្មតា** ........ ២៤

**កថាខណ្ឌទី១ ៖ ការកាត់កាល់ដោយមានការព្រមព្រៀងគ្នា** ........ ២៤

ក. កូនសុំជានីតិជន ........ ២៤

ខ. កូនសុំជាអនីតិជន ........ ២៥

គ. ពាក្យសុំកាត់កាល់ ........ ២៦

**កថាខណ្ឌទី២ ៖ ការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់** ........ ២៦

ក. អ្នកមានសិទ្ធិកាត់កាល់ ........ ២៧

ខ. ពាក្យបណ្ដឹងកាត់កាល់ ........ ២៨

**កថាខណ្ឌទី៣ ៖ អានុភាពនៃការកាត់កាល់សុំកូនធម្មតា** ........ ២៩

## ជំពូកទី៣

## សិទ្ធិរបស់កូនសុំ

**ផ្នែកទី១ ៖ សិទ្ធិរបស់កូនសុំពេញលេញ** ........ ៣០

ក. សិទ្ធិទទួលដឹងពីកំណើត ........ ៣០

ខ. សិទ្ធិប្រើប្រាស់នាមត្រកូល ........ ៣១

គ. សិទ្ធិស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្ដាយចិញ្ចឹម ........ ៣១

ឃ. សិទ្ធិទទួលបានអាហារកាតព្វកិច្ច....................................................................................................៣២
ង. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម ..........................................................................................................៣២
ច. សិទ្ធិប្ដឹងទាមទារមិតក ....................................................................................................................៣២
**ផ្នែកទី២ ៖ សិទ្ធិរបស់កូនសុំធម៌តា**.............................................................................................. ៣៣
ក. សិទ្ធិប្រើប្រាស់នាមត្រកូល ................................................................................................................ ៣៣
ខ. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹម ............... ៣៣
គ. សិទ្ធិទទួលបានអាហារកាតព្វកិច្ច ..................................................................................................... ៣៣
ឃ. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម ......................................................................................................... ៣៣
ង. សិទ្ធិប្ដឹងទាមទារមិតក ....................................................................................................................៣៤
**សេចក្ដីសន្និដ្ឋាន** ........................................................................................................................៣៥
**អានុសាសន៍** ....................................................................................................................................៣៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមបច្ចុប្បន្ននេះ មិនថាប្រទេសក្រីក្រ ឬប្រទេសដែលមានការអភិវឌ្ឍន៍ជឿនលឿនយ៉ាងណានោះទេ គឺបញ្ហាកើតមាននៅក្នុងរង្វង់គ្រួសារ តែងតែជួបប្រទះក្នុងការរស់នៅប្រចាំថ្ងៃជារឿងធម្មតាជៀសមិនផុត។ ដូច្នេះដើម្បីដោះស្រាយបញ្ហាទាំងនោះបាន ប្រទេសនីមួយៗចាំបាច់ត្រូវតែមានច្បាប់ សម្រាប់រៀបចំសណ្តាប់ធ្នាប់សង្គម ក៏ដូចជាគ្រួសារឲ្យបានល្អ។ មនុស្សម្នាក់ៗដែលរស់នៅក្នុងសង្គមតែងតែត្រូវការបង្កើតគ្រួសារមួយ តាមរយៈការបង្កើតចំណងអាពាហ៍ពិពាហ៍។ នៅប្រទេសកម្ពុជា ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ មានកំណត់ច្បាស់លាស់អំពីលក្ខខណ្ឌដែលអាចកើតមានចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រីតាមផ្លូវគតិយុត្ត និងលក្ខខណ្ឌផ្សេងៗទៀតដែលពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីបង្កើតគ្រួសារមួយតាមរយៈការរៀបអាពាហ៍ពិពាហ៍ហើយនោះ គ្រួសារនីមួយៗតែងតែមានបំណងនៅក្នុងការបង្កើតបុត្រ។ យ៉ាងណាមិញ យើងឃើញថា មានគ្រួសារមួយចំនួនដែលមានបំណងចង់បង្កើតបុត្រដែលជារបស់ខ្លួន ប៉ុន្តែពួកគាត់មិនអាចធ្វើការបង្កើតបានដោយខ្លួនឯង ដោយសារបញ្ហាផ្សេងៗដូចជា បញ្ហាសុខភាពដែលធ្វើឱ្យពួកគាត់មិនអាចធ្វើការបង្កើតកូនបានដោយខ្លួនឯង ដែលជាហេតុធ្វើឱ្យពួកគាត់បង្ខំចិត្តបោះបង់ចោលការបង្កើតបុត្រនេះ។ ដូច្នេះ តើបុគ្គលទាំងនោះពិតជាមិនអាចមានបុត្ររហូតមែនដែរទេ តើធ្វើយ៉ាងណាទើបពួកគាត់អាចមានបុត្រ ដើម្បីបំពេញចន្លោះក្នុងគ្រួសាររបស់គាត់បាន?

ដោយសារតែគេឃើញមានបញ្ហានេះតែងតែកើតឡើង ជាពិសេសចំពោះគ្រួសារដែលមានជីវភាពធូរធារប៉ុន្តែបែរជាមិនអាចមានកូនទៅវិញ ទើបរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតឲ្យមានច្បាប់ស្តីពីការសុំកូននៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។ ជាការពិត បញ្ហាពាក់ព័ន្ធនឹងការសុំកូនត្រូវបានចែងនៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារតាំងពីយូរណាស់មកហើយ ប៉ុន្តែយើងសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជាពុំទាន់ជ្រាបច្បាស់នៅឡើយថាអ្វីជាការសុំកូនដែលត្រូវបានទទួលស្គាល់ដោយច្បាប់។ ជារឿយៗ យើងតែងឃើញបុគ្គលដែលមានបង្កើតចង់ធ្វើការសុំកូន ភាគច្រើនគាត់ធ្វើការសុំកូនតាមរយៈការដោះដូរជាថវិកាជូនទៅភាគីឪពុកម្តាយបង្កើត ដើម្បីទទួលយកកូននោះមកធ្វើជាកូនចិញ្ចឹម ឬកូនសុំរបស់ខ្លួនដោយពុំបានអនុវត្តទៅតាមនីតិវិធីច្បាប់ឡើយ។ ចំពោះបុគ្គលខ្លះទៀត ធ្វើការសុំកូនក្នុងគោលបំណងទុច្ចរិត ដើម្បីយកកូនសុំនោះមកធ្វើជាអ្នកបម្រើខ្លួន និងកូនបង្កើតខ្លួន និងខ្លះទៀតឈានដល់

ការប្រើប្រាស់អំពើហិង្សាលើកូនសុំនោះទៀតផង។ បញ្ហាទាំងនេះតែងតែកើតមាន ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរទាក់ទងនឹងការសុំកូន និងសិទ្ធិរបស់កូនសុំនេះនៅមានកម្រិតនៅឡើយ។

ពាក្យថា «**សុំ**» គឺមកពីពាក្យថា សុំ មានន័យថាការសុំរបស់អ្វីពីអ្នកដទៃ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ចំណែកឯពាក្យថា «**ការសុំកូន**» យើងមិនឃើញមានពន្យល់នៅក្នុងវចនានុក្រមសម្តេចជួនណាត ក៏ដូចជាសទ្ទានុក្រមផ្នែករដ្ឋប្បវេណីទេ។ ប៉ុន្តែបើយើងក្រឡេកមើលទៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារវិញ នៅផ្នែកទី៤ដែលចែងពីសុំកូន បានឱ្យនិយមន័យពាក្យថា «**ការសុំកូន**» នេះថា ជាកិច្ចសន្យា ដែលចងបុគ្គល២ (ពីរ)នាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា[1]។ មានន័យថា ជាកិច្ចសន្យាដែលចងបុគ្គលដែលជាឪពុក ឬម្តាយចិញ្ចឹម និងកូនសុំឱ្យមានទំនាក់ទំនងនឹងគ្នា ដូចនឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើតដែរ។

ម្យ៉ាងវិញទៀត ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងការសុំកូននេះមាន២(ពីរ) ប្រភេទគឺ ការសុំកូនពេញលេញ និងការសុំកូនធម្មតា ហើយច្បាប់បានកំណត់ពីនីតិវិធីយ៉ាងត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងការបង្កើតសុំកូនទាំងនេះ។ ការបង្កើតសុំកូននេះ មិនថាសុំកូនពេញលេញ ឬសុំកូនធម្មតាគឺត្រូវធ្វើឡើងតាមរយៈតុលាការមានសមត្ថកិច្ច និងសម្រេចពីការបង្កើតសុំកូននេះតាមរយៈសេចក្តីនៃតុលាការមានសមត្ថកិច្ចនោះ។

ហេតុនេះហើយ តាមរយៈការចង្អុលបង្ហាញ និងជ្រោមជ្រែងពីសំណាក់សាស្ត្រាចារ្យណែនាំ ទើបខ្ញុំក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រ និងប្រជាពលរដ្ឋកម្ពុជាមួយរូប បានលើកយកប្រធានបទស្តីពី «**ការសុំកូន និងសិទ្ធិរបស់កូនសុំ**» នេះមកធ្វើការបកស្រាយ ដើម្បីឱ្យនិស្សិតដែលកំពុងសិក្សា និងនិស្សិតជំនាន់ក្រោយៗទៀត ក៏ដូចជាប្រជាពលរដ្ឋទូទៅបានយល់ពីបញ្ហាសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានកាន់តែច្បាស់ និងយល់ថាអ្វីខ្លះជាសិទ្ធិដែលកូនសុំអាចទទួលបានបន្ទាប់ពីការសុំកូនបានបង្កើតអានុភាពតាមច្បាប់ និងចូលរួមលុបបំបាត់ការសុំកូនដោយចេតនាទុច្ចរិត ដើម្បីការពារដល់សិទ្ធិរបស់កូនសុំគ្រប់រូបផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការរៀបរាប់ខ្លះពីខាងលើ យើងទាំងអស់គ្នាប្រាកដជាអាចយល់បានថា អ្វីទៅជាការសុំកូនដែលទទួលស្គាល់ដោយច្បាប់ និងបានដឹងទៀតថា កូនសុំមានពីរប្រភេទ។ ប៉ុន្តែអ្វីដែលយើង

[1] មាត្រា១០៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

ត្រូវដឹងបន្ថែមទៀតនោះគឺ *លក្ខខណ្ឌអ្វីខ្លះដែលច្បាប់បានកំណត់ចំពោះភាគីសុំកូន ដើម្បីបង្កើតសុំកូនទាំងពីរប្រភេទនេះបាន?* ហើយក្រោយពីការសុំកូនត្រូវបានអនុញ្ញាត និងទទួលសេចក្ដីសម្រេចពីតុលាការ *តើការសុំកូនមានអានុភាពយ៉ាងដូចម្ដេចខ្លះ?* សំណួរមួយទៀតគឺ ប្រសិនបើការទំនាក់ទំនងរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម មិនអាចមានភាពចុះសម្រុងគ្នាបាន ឬភាគីណាម្ខាងត្រូវរងទារុណកម្ម ឬអំពើហិង្សា *តើគេអាចធ្វើការកាត់កាល់សុំកូនបានដែរឬទេ ហើយតាមរបៀបណា?* និងសំណួរចុងក្រោយដែលយើងត្រូវចោទសួរនៅក្នុងប្រធាននេះគឺ *តើកូនសុំពេញលេញ និងកូនសុំធម្មតាអាចទទួលបានសិទ្ធិអ្វីខ្លះ បន្ទាប់ពីការបង្កើតសុំកូនមានអានុភាពតាមរយៈសេចក្ដីសម្រេចរបស់តុលាការ?*

## ៣. គោលបំណងនៃការស្រាវជ្រាវ

នាងខ្ញុំធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ «**ការសុំកូន និងសិទ្ធិរបស់កូនសុំនៅព្រះរាជាណាចក្រកម្ពុជា**»នេះ ក្នុងគោលបំណងចែកចាយជាពុទ្ធិសំខាន់ៗស្ដីពីការសុំកូនដែលត្រឹមត្រូវតាមផ្លូវច្បាប់ ដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ និងដើម្បីជាប្រយោជន៍សម្រាប់សិស្ស-និស្សិតក្នុងការសិក្សាស្វែងយល់បន្ថែមផង។ លើសពីនេះទៅទៀត ខ្ញុំចង់បញ្ចៀសបញ្ហារំលោភសិទ្ធិកុមារ ការប្រើអំពើហិង្សា និងទារុណកម្មលើកុមារ និងការជួញដូរកុមារជាដើម តាមរយៈរូបភាពនៃការសុំកូននេះ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទដែលខ្ញុំធ្វើការស្រាវជ្រាវនេះ គឺនឹងត្រូវសិក្សាតែក្នុងរង្វង់នៃការសុំកូនក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ដោយមិនធ្វើការបកស្រាយពីការសុំកូនអន្តរប្រទេសនោះទេ។ មួយវិញទៀត ការសិក្សាពីសិទ្ធិរបស់កូនសុំទៀតសោត ខ្ញុំនឹងលើកយកតែសិទ្ធិសំខាន់ៗដែលកូនសុំត្រូវទទួលបានប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

អ្វីដែលជាសារៈសំខាន់នៃការស្រាវជ្រាវលើប្រធានបទនេះ គឺនឹងបណ្ដុះគំនិតប្រជាពលរដ្ឋទាំងមូល ឱ្យយល់ពីបញ្ហាសុំកូនដែលមានអានុភាពគតិយុត្តតាមរយៈសេចក្ដីសម្រេចរបស់តុលាការ និងបញ្ឈប់ការសុំកូនដោយមិនមានការទទួលស្គាល់ដោយច្បាប់ និងក្នុងគោលបំណងទុច្ចរិត។ ជាងនេះទៅទៀត វាក៏អាចក្លាយជាទុនសម្រាប់និស្សិតជំនាន់ក្រោយៗទៀត ក្នុងការសិក្សាស្វែងយល់ដើម្បីជាប្រយោជន៍ក្នុងការសិក្សាថ្នាក់នីតិសាស្ត្រផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការប្រមូលទិន្នន័យ ខ្ញុំធ្វើការប្រមូលទិន្នន័យតាមរយៈពីរប្រភពគឺ ប្រភពទិន្នន័យចម្បង(ទី១) និងប្រភពទិន្នន័យបន្ទាប់បន្សំ(ទី២) ដោយធ្វើការប្រមូលទិន្នន័យទាំងនោះមកដាក់ជាបណ្តុំ ទាំងទិន្នន័យជាឯកសារ (Hard source) និងឯកសារដែលប្រមូលបានតាមរយៈអ៊ីនធើណេត (Soft source) ហើយធ្វើការវិភាគពីអត្ថន័យ និងភាពច្បាស់លាស់ ដើម្បីទទួលបានស្នាដៃមួយនេះឡើង។ ទិន្នន័យចម្បងគឺ ការសាកសួរសំនួរទៅកាន់សាស្ត្រាចារ្យណែនាំ និងសិស្សច្បងដែលមានជំនាញផ្នែកនីតិសាស្ត្រ ហើយទិន្នន័យបន្ទាប់បន្សំនោះគឺ ឯកសារនានាដែលទទួលបានពីច្បាប់លិខិតបទដ្ឋានគតិយុត្ត និងសៀវភៅផ្សេងៗដែលទទួលបានពីបណ្ណាល័យនានា ព្រមទាំងឯកសារសារណាបញ្ចប់ការសិក្សាខ្លះៗរបស់សិស្សច្បងផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណានេះ ត្រូវបានចែកចេញជា ៣ជំពូកធំៗ ដូចខាងក្រោម៖

- **ជំពូកទី ១៖ លក្ខខណ្ឌ និងអានុភាពនៃការសុំកូន ៖** នៅក្នុងជំពូកនេះ ខ្ញុំនឹងធ្វើការបកស្រាយពីការសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ថាការសុំកូននៅក្នុងប្រទេសយើង និងលក្ខខណ្ឌនានាដែលច្បាប់បានកំណត់ចំពោះភាគីនៃសុំកូន។ បន្ទាប់ពីទទួលបានការអនុញ្ញាតឱ្យបង្កើតសុំកូន យើងនឹងធ្វើការសិក្សាលើអានុភាពនៃការសុំកូននោះ។
- **ជំពូកទី២ ៖ ការកាត់កាល់សុំកូន ៖** ចំពោះជំពូកទីពីរនេះ យើងនឹងធ្វើការសិក្សា និងពន្យល់ពីការកាត់កាល់សុំកូននៅក្នុងប្រទេសកម្ពុជា ថាតើការកាត់កាល់អាចធ្វើឡើងតាមរបៀបណា និងមានអានុភាពយ៉ាងណា?
- **ជំពូកទី៣ ៖ សិទ្ធិរបស់កូនសុំ** ៖ ជំពូកទី៣ ក៏ជាជំពូកចុងក្រោយនេះ យើងនឹងធ្វើការពន្យល់ពីសិទ្ធិដែលកូនសុំនឹងទទួលបាន បន្ទាប់ពីការសុំកូនមានអានុភាពតាមផ្លូវគតិយុត្ត។

# ជំពូកទី១
# លក្ខខណ្ឌ និងអានុភាពនៃ
# ការសុំកូន

# ជំពូកទី១
# លក្ខខណ្ឌ និងអានុភាពនៃការសុំកូន

## ផ្នែកទី១ ៖ សុំកូនពេញលេញ

ការសុំកូនពេញលេញ គឺជាការសុំកូនដែលតម្រូវឱ្យភាគីដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម អនុវត្តតាមនីតិវិធីច្បាប់។ យោងតាមសន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ពាក្យថា «**សុំកូនពេញលេញ**» គឺជាការសុំអនីតិជនដែលមានអាយុក្រោម៨ (ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំដោយបញ្ចប់ញាតិភាព រវាងញាតិលោហិតនៃឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។ ដោយការសុំកូនពេញលេញ ជាការសុំកូនតាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំទៅតុលាការ។ ដូច្នេះការសុំកូនបែបនេះនឹងបង្កើតជាអានុភាពផ្លូវច្បាប់ បន្ទាប់ពីទទួលបានសេចក្ដីសម្រេចពីតុលាការ។

ការបង្កើតឲ្យមានសុំកូនពេញលេញនេះឡើង គឺដើម្បីផលប្រយោជន៍កុមារដែលខ្វះការថែរក្សា ឬការយកចិត្តទុកដាក់ពីឪពុកម្ដាយបង្កើត ឬឪពុកម្ដាយបង្កើតមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការមើលថែចិញ្ចឹមកូនបាន ដោយសារស្ថានភាពណាមួយដែលខ្លួនមាន ដូចជាបញ្ហាស្មារតី ឬពិការរាងកាយជាដើម។ ដូច្នេះ ដើម្បីបង្កើតសុំកូនពេញលេញបាន គេត្រូវគោរពតាមលក្ខខណ្ឌនានា ដែលច្បាប់បានកំណត់។

### កថាខណ្ឌទី១ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

នៅក្នុងការបង្កើតសុំកូនពេញលេញ គឺដាច់ខាតគេត្រូវតែធ្វើតាមនីតិវិធីដែលច្បាប់បានកំណត់ ហើយគេក៏បានចែងយ៉ាងច្បាស់ក្នុងមាត្រាជាច្រើននៃក្រមរដ្ឋប្បវេណី អំពីការបង្កើតសុំកូនពេញលេញនេះដែរ។ ច្បាប់ក៏បានកំណត់ពីលក្ខខណ្ឌ មុននឹងអនុញ្ញាតឱ្យមានការបង្កើតសុំកូនពេញលេញឡើង។ លក្ខខណ្ឌធំៗនៃការបង្កើតសុំកូនពេញលេញ ក៏មានលក្ខណៈមិនខុសគ្នាពីលក្ខខណ្ឌនៃការបង្កើតកិច្ចសន្យានានាដែរ គឺមានលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

#### ក. លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌគ្រឹះ គឺមានលក្ខណៈផ្ទុយពីលក្ខខណ្ឌទម្រង់ត្រង់ថា គេពុំបានផ្ដោតសំខាន់លើការដាក់ពាក្យ ឬទម្រង់នៃការដាក់ពាក្យលើក្រដាសនោះទេ ប៉ុន្តែជាលក្ខខណ្ឌចាំបាច់ដែលតុលាការត្រូវយកមកធ្វើការវិនិច្ឆ័យ មុននឹងសម្រេចឲ្យមានការបង្កើតសុំកូនពេញលេញ។ ចំពោះបុគ្គលដែលមានបំណងចង់បង្កើតសុំកូនពេញលេញ គឺត្រូវតែបំពេញតាមលក្ខខណ្ឌដែលច្បាប់បានចែងទាំងនេះ។ គេបានកំណត់លក្ខខណ្ឌផ្សេងៗគ្នា ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និងកូនសុំ ក៏ដូចជាឪពុកម្ដាយបង្កើតរបស់កូនសុំដែរ។

### ក.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម

លក្ខខណ្ឌគ្រឹះ ដែលច្បាប់កំណត់ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម មានដូចជា លក្ខខណ្ឌអាយុ អំពីសហព័ទ្ធ និងសំខាន់បំផុតនោះគឺស្ថានភាពគ្រួសាររបស់បុគ្គលនោះផ្ទាល់តែម្តង។

- **លក្ខខណ្ឌគ្រួសារ**

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មាត្រា១០០៨ (កថាខណ្ឌទី១) បានកំណត់ពីការសហការរវាងសហព័ទ្ធក្នុងការបង្កើតការសុំកូនពេញលេញ ដោយបានបញ្ជាក់យ៉ាងច្បាស់ថា បុគ្គលដែលចង់ក្លាយជាឪពុក ឬម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[2]។ ម្យ៉ាងវិញទៀត បុគ្គលដែលមានសហព័ទ្ធហើយក្តី ប៉ុន្តែការសុំកូនពេញលេញមិនមែនអាចធ្វើឡើងតាមតែការសម្រេចចិត្តរបស់សហព័ទ្ធតែម្ខាងនោះទេ។ សហព័ទ្ធទាំងសងខាងត្រូវតែសហការគ្នា ក្នុងការសម្រេចចិត្តបង្កើតការសុំកូនពេញលេញនេះឡើង។ យ៉ាងណាមិញ យើងឃើញថានៅមាត្រា១០០៨ នៃក្រមដដែល (កថាខណ្ឌទី២) បានចែងថា ប្តី ឬប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬឪពុកចិញ្ចឹម។ មានន័យថាសហព័ទ្ធទាំងសងខាង ត្រូវតែធ្វើការយល់ព្រមនៅក្នុងការបង្កើតសុំកូនពេញលេញនេះ ទើបអ្នកទាំងពីរអាចដាក់ពាក្យសុំបង្កើតសុំកូនទៅតុលាការបាន។ ប៉ុន្តែ ប្បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត[3]។ ដោយយោងតាមកថាខណ្ឌទី២ នៃមាត្រា១០០៨នេះ យើងអាចសន្និដ្ឋានបានថា ក្នុងករណីដែលសហព័ទ្ធម្ខាងដែលមានកូន ហើយបានមករៀបអាពាហ៍ពិពាហ៍ជាមួយសហព័ទ្ធម្ខាងទៀត ដូច្នេះសហព័ទ្ធម្ខាងទៀតនោះ នឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូននោះដោយពុំចាំបាច់មានការយល់ព្រមពីសហព័ទ្ធម្នាក់ទៀតឡើយ។

ឧទាហរណ៍៖ A បានរៀបអាពាហ៍ពិពាហ៍ជាមួយប្តីមុនបានកូនចំនួន១(មួយ)នាក់ បន្ទាប់មកក៏បានលែងលះគ្នា ហើយ A ក៏បានយកកូនដែលមានជាមួយប្តីមុននោះមករស់នៅជាមួយខ្លួន។ មិនយូរប៉ុន្មាន A ក៏បានរៀបអាពាហ៍ពិពាហ៍ជាថ្មីម្តងទៀតជាមួយ B ដូច្នេះ Bបានក្លាយជាឪពុកចិញ្ចឹមរបស់កូនរបស់ A ដោយពុំចាំបាច់មានការយល់ព្រមពី A នោះទេ។

- **លក្ខខណ្ឌអាយុ**

ឪពុកម្តាយចិញ្ចឹមដែលមានបំណងចង់ធ្វើការសុំកូនពេញលេញត្រូវតែមានអាយុចាប់ពី២៥

[2] មាត្រា១០០៨ កថាខណ្ឌទី១ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[3] មាត្រា១០០៨ កថាខណ្ឌទី២ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

(ម្ភៃប្រាំ)ឆ្នាំឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ (ម្ភៃ)ឆ្នាំ[4]។ បើបុគ្គលណាម្នាក់ដែលចង់សុំកូនពេញលេញ ហើយមិនមានអាយុស្របនឹងអ្វីដែលច្បាប់បានចែងទេ នោះគេនឹងមិនមានសិទ្ធិនៅក្នុងការបង្កើតសុំកូនពេញលេញនោះទេ។ យើងឃើញថា ច្បាប់បានកំណត់ថាបុគ្គលដែលចង់បង្កើតសុំកូនពេញលេញ ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ដូច្នេះចំពោះលក្ខខណ្ឌដែលតម្រូវឱ្យមានអាយុចាប់ពី២៥ (ម្ភៃប្រាំ)ឆ្នាំឡើងទៅនោះ គឺត្រូវយកទៅអនុវត្តចំពោះសហព័ទ្ធទាំងពីរ ពោលគឺពួកគេទាំងពីរនាក់ត្រូវមានអាយុចាប់ពី២៥ (ម្ភៃប្រាំ)ឆ្នាំឡើងទៅដូចគ្នា។ ការបង្កើតឱ្យមានលក្ខខណ្ឌដែលកំណត់ពីអាយុរបស់ឪពុកម្ដាយចិញ្ចឹមនោះ គឺដើម្បីធ្វើយ៉ាងណាបញ្ចៀសភាពមិនប្រក្រតីណាមួយនៃការសុំកូននេះ។ ជាទូទៅ ការសុំកូនពេញលេញត្រូវបានធ្វើឡើង ក្នុងគោលបំណងបង្កើតគ្រួសារមួយដែលមានលក្ខណៈប្រក្រតីដូចគ្រួសារផ្សេងទៀត។ ផ្ទុយទៅវិញ បើអាយុរបស់ឪពុកម្ដាយចិញ្ចឹមនោះក្មេងពេក និងមានភាពប្រហាក់ប្រហែលគ្នាទៅនឹងអាយុរបស់កូនសុំពេញលេញ នោះវានឹងបង្កើតជាភាពមន្ទិលនានាអំពីមនុស្សជុំវិញខ្លួន។ ហេតុនេះហើយ ទើបច្បាប់កំណត់ឱ្យឪពុកម្ដាយចិញ្ចឹមត្រូវតែមានអាយុច្រើនជាងកូនសុំយ៉ាងតិច២០ (ម្ភៃ)ឆ្នាំ។ ម្យ៉ាងវិញទៀត យើងឃើញថា បើឪពុកម្ដាយចិញ្ចឹមមានអាយុក្មេងពេក អ្វីដែលជាមូលហេតុតម្រូវឱ្យពួកគេធ្វើការបង្កើតការសុំកូនពេញលេញឡើង ហើយតើពួកគេអាចមានលទ្ធភាពផ្តល់ឱ្យកូនសុំពេញលេញនោះ នូវគ្រួសារដែលមានជីវភាពធូរធា និងសមរម្យដែរទេ?

យ៉ាងណាមិញ ទោះជានៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់ពីអាយុអប្បបរិមារបស់ឪពុកម្ដាយចិញ្ចឹម និងគម្លាតអាយុរវាងឪពុកម្ដាយចិញ្ចឹមនឹងកូនសុំពិតមែន ប៉ុន្តែយើងមិនឃើញមានមាត្រាណាមួយបានកំណត់ពីអាយុអតិបរមារបស់ឪពុកម្ដាយចិញ្ចឹមនោះឡើយ។ ដូចនេះ យើងអាចសន្និដ្ឋានបានថា ជនគ្រប់រូប ទោះជាមានអាយុច្រើនក្តី ឬក៏ជាមនុស្សចាស់ក្តី ក៏អាចបង្កើតសុំកូនពេញលេញតាមច្បាប់បានដែរ ឱ្យតែបានបំពេញលក្ខខណ្ឌផ្សេងៗទៀតដែលច្បាប់បានកំណត់។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ តុលាការនៅតែអាចប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីធ្វើការសម្រេចពីការបង្កើតសុំកូនពេញលេញនេះ។

- **លក្ខខណ្ឌសមត្ថភាព**

ចំពោះជនដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម មិនមានមាត្រាណាមួយនៃច្បាប់បានចែងពីសមត្ថភាពរបស់ពួកគាត់នោះទេ នៅក្នុងការបង្កើតសុំកូនពេញលេញទេ។ មិនថាជននោះជា

[4] មាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ជនដែលត្រូវបានកំរិតសមត្ថភាព ដូចជាជនដែលស្ថិតក្រោមអាណាព្យាបាលទូទៅជាដើម[5]។ ទោះជាមិនមានការបញ្ជាក់ណាមួយច្បាស់លាស់ក្នុងហាមជនទាំងនោះមិនឲ្យបង្កើតសុំកូនពេញលេញក៏ដោយ ក៏នៅក្នុងស្ថានភាពសង្គមជាក់ស្តែង ជនដែលត្រូវបានកម្រិតសមត្ថភាពពិតប្រាកដណាស់ថា ពុំអាចធ្វើការចិញ្ចឹមបីបាច់កូនសុំនោះ ដូច្នេះតុលាការនឹងធ្វើការវិនិច្ឆ័យមុននឹងសម្រេចឲ្យមានការសុំកូនពេញលេញ។ ដោយហេតុថា ការបង្កើតសុំកូនពេញលេញនេះគឺស្ថិតក្នុងគោលបំណងចង់បង្កើត និងផ្តល់គ្រួសារមួយល្អប្រសើរ និងភាពចាំបាច់ពិសេសនានាដើម្បីជាប្រយោជន៍ដល់កូននោះ[6]។ ដូច្នេះ បើឪពុក ឬម្តាយចិញ្ចឹមគឺជាជនដែលត្រូវបានកម្រិតសមត្ថភាព នោះគេសន្និដ្ឋានថាមិនអាចផ្តល់ការថែទាំពេញលេញដល់កូនសុំនោះបានទេ។

**ក.២. លក្ខខណ្ឌចំពោះកូនសុំ**

ចំពោះកុមារដែលនឹងក្លាយជាកូនសុំវិញ ឃើញច្បាស់ថាច្បាប់មិនបានកំណត់ពីលក្ខខណ្ឌអ្វីច្រើនទេ គឺផ្តោតតែលើចំណុចសំខាន់ ២យ៉ាងគឺ អាយុរបស់កុមារនោះ និងស្ថានភាពដែលកុមារនោះរស់នៅសព្វថ្ងៃជាមួយនឹងឪពុកម្តាយបង្កើត ឬជាអ្នកមានអំណាចមេបាលើគេតែប៉ុណ្ណោះ។

- **លក្ខខណ្ឌអាយុ**

គោលការណ៍បានកំណត់ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺតម្រូវឱ្យកូនសុំពេញលេញត្រូវមានអាយុតិចជាង៨ (ប្រាំបី)ឆ្នាំ[7]។ មានមនុស្សមួយចំនួនបានលើកឡើងថា អ្វីទៅជាការចាំបាច់ដែលត្រូវកំណត់ពីអាយុរបស់កូនសុំនោះ? យើងអាចធ្វើការបកស្រាយតាមស្ថានភាពទូទៅបានថា ការកំណត់ពីអាយុរបស់កូនសុំពេញលេញឱ្យតិចជាង៨ (ប្រាំបី)ឆ្នាំនេះ ព្រោះថានៅក្នុងការបង្កើតសុំកូនពេញលេញ តាមច្បាប់នឹងតម្រូវឱ្យមានការកាត់ផ្តាច់ញាតិភាពរវាងកូនសុំ នឹងឪពុកម្តាយបង្កើត រួមទាំងបងប្អូន និងសាច់ញាតិបង្កើតដែរ[8]។ ដូច្នេះ បើកូនសុំពេញលេញមានអាយុច្រើនពេកនោះ សមត្ថភាពក្នុងការយល់ដឹង និងការចងចាំសាច់ញាតិ និងឪពុកម្តាយបង្កើតរបស់គេនឹងកាន់តែមានកំរិតខ្ពស់ដូចនេះវានឹងមានភាពលំបាកចំពោះកូនសុំ ក៏ដូចជាឪពុក ម្តាយចិញ្ចឹម បន្ទាប់ពីបានបង្កើតសុំកូនពេញលេញហើយនោះ។ យ៉ាងណាមិញ យើងឃើញថានៅតែមានមតិខ្លះបានលើកឡើងថា នៅក្រមរដ្ឋប្បវេណីពុំបានបញ្ជាក់ច្បាស់អំពីលក្ខខណ្ឌអាយុរបស់កូនសុំនេះទេ គេគ្រាន់តែចែងថា «តាមគោល

[5] មាត្រា១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[6] មាត្រា១០១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[7] មាត្រា១០១០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[8] មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ការណ៍» ប៉ុណ្ណោះ។ ហេតុដូច្នេះ ទើបមានការសន្និដ្ឋានថា ចំពោះអាយុជាក់លាក់របស់កូនសុំអាចច្រើនជាង៨ (ប្រាំបី)ឆ្នាំ ឬយ៉ាងណានោះ ត្រូវសម្រេចដោយឆន្ទានុសិទ្ធិរបស់តុលាការ ថាតើការបង្កើតការសុំកូនពេញលេញនោះអាចធ្វើបានឬទេ ក្នុងករណីដែលកូននោះមានអាយុច្រើនជាង៨ (ប្រាំបី)ឆ្នាំ។ យ៉ាងណាក៏ដោយ តុលាការគួរតែធ្វើការពិចារណាលើកម្រិតអាយុរបស់កូនសុំឱ្យបានច្បាស់លាស់ មុននឹងអនុញ្ញាតិឱ្យមានការសុំកូនពេញលេញ ដោយពុំគួរឱ្យកូនសុំមានអាយុច្រើនពេកទេ បើពុំដូច្នោះទេវាអាចបង្កឲ្យមានផលវិបាកទៅថ្ងៃមុខដូចដែលយើងបានលើកឡើងខាងលើ។

ក្នុងករណីដែលឪពុកម្ដាយចិញ្ចឹមបានចិញ្ចឹមកូនសុំនោះតាំងពីតូចមក ប៉ុន្តែមិនបានធ្វើការសុំកូនតាមច្បាប់ ហើយមានបំណងចង់បង្កើតសុំកូនពេញលេញនៅថ្ងៃអនាគត គេអាចបង្កើតសុំកូនពេញលេញបាន ទោះបីជាកូននោះមានអាយុលើសពី៨ (ប្រាំបី)ឆ្នាំក្តីនៅពេលដាក់ពាក្យសុំ[9]។ ប៉ុន្តែយ៉ាងណាមិញ គេត្រូវឆ្លងកាត់ការសម្រេចសេចក្តីពីតុលាការជាមុនសិន មុននឹងអាចបង្កើតសុំកូនពេញលេញតាមផ្លូវច្បាប់។

- **ស្ថានភាពគ្រួសារ**

ក្រៅពីលក្ខខណ្ឌអាយុរបស់កូនសុំខាងលើនេះ ចំនុចដែលសំខាន់មួយទៀតដែលគេត្រូវយកមកវិនិច្ឆ័យមុននឹងសម្រេចឱ្យមានការសុំកូននោះគឺ ស្ថានភាពគ្រួសារ និងការរស់នៅរបស់កូនសុំជាមួយនឹងឪពុកម្ដាយបង្កើត។ បើឪពុកម្ដាយបង្កើតរបស់កូននោះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងអាចផ្តល់គ្រួសារមួយដ៏ល្អដល់កូននោះហើយ នោះការសុំកូនពេញលេញក៏ពុំចាំបាច់ត្រូវបង្កើតឡើងដែរ។ យើងត្រូវវិនិច្ឆ័យមើលថា ស្ថានភាពគ្រួសាររបស់ឪពុកម្ដាយបង្កើតនៃក្មេងនោះមានលក្ខណៈក្រលំបាកខ្លាំង ឬយ៉ាងណា[10]? តើក្មេងអាចទទួលបានការថែទាំល្អពីឪពុកម្ដាយបង្កើតទេ? តើក្មេងមានទទួលរងទារុណកម្ម ឬអំពើហិង្សាពីសំណាក់ឪពុកម្ដាយបង្កើតដែរឬទេ? ចំនុចទាំងនេះគ្រាន់តែជាមូលដ្ឋានសម្រាប់ធ្វើការពិចារណាពីស្ថានភាពរបស់កុមារមុននឹងសម្រេចបង្កើតសុំកូនពេញលេញ។ ក្រៅពីនេះ យើងក៏ត្រូវក្រឡេកមើលលើស្ថានភាពគ្រួសាររបស់ជនដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមដែរ ថាមានស្ថានភាពបែបណា? មូលហេតុដែលយើងចាប់យកចំនុចទាំងនោះមកធ្វើការពិចារណា ដើម្បីបញ្ចៀសផលអវិជ្ជមានផ្សេងៗដែលកើតពីរូបភាពនៃការសុំកូននេះដូចជា ការជួញដូរកុមារ។

[9] កម្មវិធីបង្ហាញច្បាប់នៃវិភាគទានច្បាប់ទាក់ទងនឹងប្រធានបទ «ការចិញ្ចឹមកូនតាមផ្លូវច្បាប់(សុំកូនពេញលេញ)» ដោយលោក ស៊ិន ច័ន្ទផល្គុន សមាជិកវគ្គបណ្តុះបណ្តាលពិសេសជំនាន់ទី១ នៃវិភាគទានច្បាប់។
[10] មាត្រា១០១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ក.៣. លក្ខខណ្ឌផ្សេងៗទៀត

**• ការយល់ព្រមពីឪពុកម្តាយបង្កើត**

យើងត្រូវសុំការអនុញ្ញាតពីម្ចាស់ជាមុនសិន មុននឹងអាចយករបស់អ្នកដទៃមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនបាន បើពុំនោះទេ វានឹងបង្កើតជាបទល្មើសលួចមិនខាន នេះគ្រាន់តែជាឧទាហរណ៍សាមញ្ញមួយតែប៉ុណ្ណោះ។ ចំពោះការដែលយើងចង់បានកូនរបស់អ្នកដទៃមកចិញ្ចឹមដើម្បីឲ្យក្លាយជាកូនខ្លួនក៏ដូច្នោះដែរ ច្បាស់ណាស់យើងត្រូវតែសុំការអនុញ្ញាត និងការយល់ព្រមពីសំណាក់ឪពុកម្តាយបង្កើតរបស់ក្មេងជាមុនសិន។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ជាក់ថា ដើម្បីបង្កើតស្មុំកូនពេញលេញបាន ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដែលនឹងក្លាយជាកូនសុំនោះ[11]។ ប៉ុន្តែការសុំការយល់ព្រមពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលអនីតិជននេះ ពុំត្រូវបានយកមកអនុវត្តគ្រប់ពេលនោះទេ។ ជាក់ស្តែង ដូចជាករណីដែលឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់ក្មេងមិនអាចបង្ហាញឆន្ទៈបាន ឬក្មេងទទួលរងការធ្វើបាបដោយអំពើហិង្សាពីឪពុកម្តាយបង្កើត ឬឪពុកម្តាយបង្កើតបានបោះបង់ចោលក្មេងនោះដោយគំនិតទុច្ចរិត ឬ មូលហេតុផ្សេងៗទៀត ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ធ្ងន់ធ្ងរ ក្នុងករណីនេះគេពុំចាំបាច់សុំការយល់ព្រមពីឪពុកម្តាយបង្កើតរបស់ក្មេងនោះទេ[12]។ ក្នុងករណីដែលក្មេងមិនមានឪពុកម្តាយបង្កើត ហើយរស់នៅជាមួយពូមីងជាដើម ប៉ុន្តែបើសាច់ញាតិទាំងនោះមិនមែនជាអាណាព្យាបាលសម្រាប់អនីតិជន ដោយត្រឹមត្រូវតាមច្បាប់ទេ នោះគេក៏មិនចាំបាច់ទទួលការយល់ព្រមពីពួកគេទាំងនោះដែរ។

**• ការសាកល្បងចិញ្ចឹម**

ដើម្បីការពារផលប្រយោជន៍កូនសុំ ការផ្តល់គ្រួសារដ៏ល្អមួយដល់គេ ដើម្បីជៀសផុតពីការរំលោភបំពាន និងគេចផុតពីភាពលំបាកនានាដែលកើតឡើងជាមួយឪពុកម្តាយចិញ្ចឹម គេត្រូវតែបង្កើតឱ្យមានការសាកល្បងចិញ្ចឹម។ គេត្រូវធានាថា ឪពុកម្តាយចិញ្ចឹមពិតជាជនដែលអាចផ្តល់ភាពកក់ក្តៅ និងចិញ្ចឹមបីបាច់កូននោះក្នុងគោលបំណងសុច្ចរឹត និងពិតជាអាចផ្តល់ភាពជាគ្រួសារដ៏ល្អដល់កូននោះពិតមែន។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីការសាកល្បងចិញ្ចឹមកូនសុំដែរថា ជាគោលការណ៍ ឪពុកម្តាយចិញ្ចឹមត្រូវប្រើប្រាស់រយៈពេលយ៉ាងតិច៦ (ប្រាំមួយ)ខែ ក្នុងការសាកល្បងចិញ្ចឹមកូនសុំ មុននឹងត្រូវបានអនុញ្ញាតឱ្យមានស្មុំ

[11] មាត្រា១០១១ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[12] មាត្រា១០១១ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កូនពេញលេញ[13]។ អំឡុងពេលសាកល្បងចិញ្ចឹមនេះនឹងត្រូវបានសម្រេចដោយតុលាការ តុលាការត្រូវធ្វើការពិចារណាលើសកម្មភាព និងអាកប្បកិរិយាដែលបុគ្គលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ក៏ដូចជាមើលលើស្ថានភាព និងភាពចុះសម្រុងគ្នារវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមផងដែរ ក្នុងអំឡុងពេលសាកល្បងចិញ្ចឹមនេះ មុននឹងធ្វើការសម្រេចពីការផ្តល់សិទ្ធិឱ្យបង្កើតស្មុំកូនពេញលេញនេះបាន។

- **ចំនួនកូនស្មុំ**

ក្នុងការបង្កើតស្មុំកូនពេញលេញ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាពុំបានបញ្ជាក់ក្នុងមាត្រាណាមួយឡើយ ពីចំនួនកូនស្មុំដែលគេអាចធ្វើការសុំបាន។ ប៉ុន្តែយោងតាមច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារវិញបានកំណត់ថា គេអាចសុំកូនបានត្រឹម២ (ពីរ)នាក់ប៉ុណ្ណោះ។ ប៉ុន្តែបើកូនដែលសុំមកនោះ មានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន[14]។ យ៉ាងណាមិញ មិនមានមាត្រាណាមួយនៃច្បាប់ បានបញ្ជាក់ពីមូលហេតុដែលកំណត់ឲ្យមានការស្មុំកូនក្នុងចំនួនកំណត់ខាងលើនោះទេ។

### ខ. លក្ខខណ្ឌទម្រង់

ដូចដែលយើងបានបញ្ជាក់ខាងលើថា ក្រៅពីលក្ខខណ្ឌគ្រឹះហើយនោះ បុគ្គលដែលចង់បង្កើតស្មុំកូនពេញលេញត្រូវបំពេញទៅតាមលក្ខខណ្ឌទម្រង់ទៀត បើពុំដូច្នោះទេគេមិនចាត់ទុកថាបានបង្កើតស្មុំកូនឡើងទេ។ លក្ខខណ្ឌទម្រង់គឺសំដៅដល់ការដាក់ពាក្យសុំទៅតុលាការដើម្បីសុំបង្កើតស្មុំកូនពេញលេញនេះ។ មុននឹងយើងអាចធ្វើការដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ យើងក៏ត្រូវស្វែងយល់ពីអ្នកដែលមានសិទ្ធិនៅក្នុងការដាក់ពាក្យ របៀបដាក់ពាក្យ ទម្រង់នៃពាក្យសុំនោះ និងសមត្ថកិច្ចដែលមានតួនាទីទទួលពាក្យនោះ។

#### ខ.១. ការដាក់ពាក្យ និងអ្នកដែលមានសិទ្ធិដាក់ពាក្យសុំ

នៅក្នុងការដាក់ពាក្យសុំបង្កើតស្មុំកូនពេញលេញ គឺតម្រូវឱ្យបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមនោះ ធ្វើការដាក់ពាក្យដោយផ្ទាល់ ហើយពាក្យសុំនោះត្រូវយកទៅដាក់នៅតុលាការ[15]។ ហេតុផលដែលត្រូវធ្វើការដាក់ពាក្យសុំដល់តុលាការគឺ ដើម្បីទទួលបានការវិនិច្ឆ័យមួយដ៏ត្រឹមត្រូវជូនដល់កុមារ។ តុលាការនឹងធ្វើការស្រាវជ្រាវ និងវិនិច្ឆ័យខ្ពស់មុននឹងធ្វើការសម្រេចឲ្យមានការស្មុំកូននេះ ដើម្បីធានាដល់សុវត្ថិភាព និងប្រយោជន៍របស់កុមារនោះ។

---

[13] មាត្រា១០១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[14] មាត្រា១១០ (វាក្យខណ្ឌទី១&២) នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩។

[15] មាត្រា១០០៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ចំពោះឪពុកម្ដាយចិញ្ចឹមដែលជាអ្នកមានសិទ្ធិនៅក្នុងការដាក់ពាក្យ ហើយពាក្យសុំនោះត្រូវតែមានការឯកភាពពីសំណាក់សហព័ទ្ធទាំងសងខាង។ ប៉ុន្តែយើងមិនយកមកអនុវត្តចំពោះករណីដែលសហព័ទ្ធម្ខាងទទួលយកកូនរបស់សហព័ទ្ធម្ខាងទៀតមកចិញ្ចឹមនោះទេ។ ចំពោះករណីនេះ សហព័ទ្ធតែម្ខាង ដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមអាចធ្វើការដាក់ពាក្យសុំតែម្នាក់ឯងបាន។

**ខ.២. ទម្រង់នៃពាក្យសុំ**

ដោយយោងតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង បានចែងពីរបៀបនៃការដាក់ពាក្យសុំទៅតុលាការទូទៅ ក៏ដូចជាទម្រង់នៃការដាក់ពាក្យសុំបង្កើតស៊ុំកូនពេញលេញដែរ។ ចំណុចដែលអ្នកដាក់ពាក្យសុំត្រូវសរសេរនៅក្នុងពាក្យសុំនោះមានដូចជា៖

១. ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬច្បាប់ផ្សេងទៀត។

២. នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំនុចដូចខាងក្រោមនេះ៖

**ក.** ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

**ខ.** ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

៣. ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្ដីថ្លែងការណ៍ចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនោះ ត្រូវបានចាត់ទុកជាលិខិតពាក្យសុំ។

៤. ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់ឯកសារដើម ឬឯកសារចម្លង ដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ។ [16]

**ខ.៣. ស្ថាប័នទទួលពាក្យសុំ**

ដូចដែលយើងបានរៀបរាប់ និងបង្ហាញខ្លះៗពីចំណុចខាងលើថា ពាក្យសុំដែលធ្វើដោយអ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំនេះត្រូវយកទៅដាក់នៅតុលាការ ដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេចពីការបង្កើតស៊ុំកូនពេញលេញ។ ប៉ុន្តែ សំនួរសួរថាតើអ្នកដាក់ពាក្យសុំ

[16] មាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

នោះត្រូវយកពាក្យសុំ ទៅដាក់នៅតុលាការមួយណា នៅឯណា?

ដោយយោងតាមតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានចែងថាតុលាការដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចពីការបង្កើតសុំកូនពេញលេញនេះ គឺតុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម[17]។

**កថាខណ្ឌទី២ ៖ អានុភាពនៃសុំកូនពេញលេញ**

បន្ទាប់ពីស្វែងយល់ពីលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃការបង្កើតសុំកូនពេញលេញហើយ យើងគួរគប្បីយល់ពីអានុភាពនៃសុំកូនពេញលេញម្តង។ ជាទូទៅ នៅពេលបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម បានបំពេញលក្ខខណ្ឌទាំងឡាយខាងលើដែលច្បាប់បានកំណត់ ហើយទទួលបានសេចក្តីសម្រេចពីតុលាការឱ្យបង្កើតសុំកូនពេញលេញបាន នោះច្បាស់ណាស់ថាវានឹងបង្កើតអានុភាពតាមផ្លូវច្បាប់។

តើសុំកូនពេញលេញនឹងបង្កើតអានុភាពតាមផ្លូវច្បាប់បែបណាខ្លះ? ចំពោះអានុភាពនៃសុំកូនពេញលេញ ក្រមរដ្ឋប្បវេណីបានចែងពី ២ចំនុចគឺ ការបង្កើតញាតិភាពថ្មីមួយជាមួយឪពុកម្តាយចិញ្ចឹម និងការបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើត និងញាតិលោហិតដែរ។

**ក. ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម**

ការបង្កើតសុំកូនពេញលេញ មានគោលបំណងចម្បងក្នុងការបង្កើតគ្រួសារថ្មីមួយដែលមានលក្ខណៈពេញលេញដូចជាគ្រួសារដទៃដល់ក្មេងដែលជាកូនសុំ ដូច្នេះការបង្កើតញាតិភាពរវាងកូនសុំនឹងឪពុកម្តាយបង្កើតគឺជារឿងមួយដែលសំខាន់បំផុត។ នៅពេលដែលការសុំកូនពេញលេញចាប់ផ្តើមមានអានុភាព នោះទំនាក់ទំនងញាតិរវាងកូនសុំនឹងឪពុកម្តាយចិញ្ចឹម ក៏ដូចជារវាងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ នឹងត្រូវបានបង្កើតដូចគ្នា[18]។ កូនសុំនឹងត្រូវក្លាយជាកូនពេញលេញតាមផ្លូវច្បាប់របស់ឪពុកម្តាយចិញ្ចឹមនោះ ហើយសិទ្ធិ និងករណីយកិច្ចរបស់កូនសុំនឹងមានភាពដូចគ្នាទៅនឹងសិទ្ធិ និងករណីយកិច្ចរបស់កូនបង្កើតដែរ។ កូនសុំត្រូវស្ថិតក្រោមការគ្រប់គ្រងពីឪពុកម្តាយចិញ្ចឹម ហើយការបង្កើតញាតិភាពតាមផ្លូវច្បាប់ជាមួយឪពុកម្តាយចិញ្ចឹមនេះ ក៏ធ្វើឱ្យញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវកាត់ផ្តាច់ដែរ។

**ខ. ការផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត**

យើងឃើញថាបន្ទាប់ពីការសុំកូនពេញលេញមានអានុភាពតាមផ្លូវច្បាប់ហើយនោះ កូនសុំនឹងក្លាយជាកូនពេញសិទ្ធិរបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះការផ្តាច់ទំនាក់ទំនងញាតិភាពជាមួយឪពុក

[17] ចំណុចទី៧ នៃផ្នែកទី៤ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។
[18] មាត្រា៩៨០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនឹងត្រូវអនុវត្ត[19]។ ការផ្តាច់ទំនាក់ទំនងញាតិរវាងកូន និង ឪពុកម្តាយបង្កើតនេះ នាំឱ្យឪពុកម្តាយបង្កើតបាត់បង់សិទ្ធិដែលជាអ្នកមានអំណាចមេបាលើកូន មានដូចជា៖

- សិទ្ធិធ្វើការអប់រំកូន
- សិទ្ធិកំណត់ពីកន្លែងស្នាក់នៅរបស់កូនសុំ
- សិទ្ធិដាក់ទណ្ឌកម្មលើកូន
- សិទ្ធិទាមទារកូនពីឪពុកម្តាយចិញ្ចឹមដែលកំណត់ដោយច្បាប់។

ប៉ុន្តែប្បញ្ញត្តិខាងលើនេះមិនត្រូវយកមកអនុវត្តឡើយចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និងញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះដែលជាសហព័ទ្ធនឹងឪពុក ឬម្តាយចិញ្ចឹម[20] ពោលគឺករណីដែលប្តីប្រពន្ធម្ខាងក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត[21]។

ការផ្តាច់ញាតិភាពជាមួយឪពុកម្តាយបង្កើត នាំឱ្យកូន និងឪពុកម្តាយបង្កើតក្លាយជាអ្នកដទៃលែងជាប់សាច់ឈាមជាមួយគ្នាបន្តទៅទៀត ញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវក្លាយជាអ្នកដទៃដូចគ្នា[22]។ គោលបំណងដែលតម្រូវឱ្យមានការផ្តាច់ទំនាក់ទំនងពីឪពុកម្តាយបង្កើត និងសាច់ញាតិបង្កើតនោះគឺ ដើម្បីជៀសវាងការរំខាននានាដែលនឹងកើតឡើងពីឪពុកម្តាយបង្កើតលើកូនសុំនោះ។

ជាទូទៅ នៅក្នុងក្រមរដ្ឋប្បវេណីបានចែងថា អាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី)ថ្នាក់ រាប់ទាំងថ្នាក់ទី៣ (បី)ផង[23]។ សំនួរសួរថា នៅពេលកូនសុំ បានផ្តាច់ចំណងញាតិភាពជាមួយឪពុកម្តាយបង្កើត រួមទាំងញាតិលោហិតរបស់ខ្លួនហើយនោះ តើអាពាហ៍ពិពាហ៍រវាងកូនសុំ និងបុគ្គលដែលបានរៀបរាប់ខាងលើ អាចធ្វើទៅបានឬទេ? យើងឃើញថា ទោះបីជាកូនសុំបានធ្វើការផ្តាច់ទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយបង្កើត រួមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតហើយក្តី ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍

[19] មាត្រា១០១៩ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[20] មាត្រា១០១៩ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[21] មាត្រា១០០៨ កថាខណ្ឌទី២ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[22] មាត្រា១០១៩ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[23] មាត្រា៩៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ (បី)ផងនោះ នៅតែត្រូវបានហាមឃាត់ដដែល[24]។

## ផ្នែកទី២ ៖ សុំកូនធម្មតា

បន្ទាប់ពីបានសិក្សាពីការសុំកូនពេញលេញហើយនោះ ការសុំកូននៅព្រះរាជាណាចក្រកម្ពុជានៅមានមួយប្រភេទទៀតដែលយើងពុំទាន់បានធ្វើការសិក្សា នោះគឺការសុំកូនធម្មតា។ តើអ្វីទៅជាការសុំកូនធម្មតា ហើយវាមានភាពខុសគ្នាពីការសុំកូនពេញលេញយ៉ាងណាខ្លះ?

«**ការសុំកូនធម្មតា**» ជាការសុំកូន ដែលកូននោះអាចជាអនីតិជន ឬនីតិជន ដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។ ចំណុចខុសគ្នារវាងការសុំកូនពេញលេញ និងការសុំកូនធម្មតា គឺមានច្រើនចំណុចដូចជា លក្ខខណ្ឌទាំងចំពោះឪពុកម្តាយចិញ្ចឹម និងចំពោះកូនសុំ គឺសុទ្ធតែមានលក្ខណៈខុសគ្នា ដែលយើងនឹងធ្វើការបកស្រាយនៅខាងក្រោមនេះ។

### កថាខណ្ឌទី១ ៖ លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

ក្រោយពីយើងសិក្សាស្វែងយល់លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញហើយ យើងគួរយល់ដឹងលក្ខខណ្ឌនៃការបង្កើតសុំកូនមួយប្រភេទទៀត គឺសុំកូនធម្មតា។ លក្ខខណ្ឌធំៗ នៃការបង្កើតសុំកូនធម្មតាក៏មិនមានអ្វីខុសពីការសុំកូនពេញលេញដែរ គឺមានលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

#### ក. លក្ខខណ្ឌគ្រឹះ

លក្ខខណ្ឌគ្រឹះនៃការបង្កើតសុំកូនធម្មតា មានលក្ខណៈមិនស្មុគស្មាញដូចការបង្កើតសុំកូនពេញលេញនោះទេ ពោលគឺច្បាប់មិនបានរឹតបន្តឹងខ្លាំងលើលក្ខខណ្ឌទាំងនេះទេ ព្រោះថាការបង្កើតសុំកូនធម្មតា គេបានផ្តល់សិទ្ធិអាទិភាពច្រើនឱ្យជនដែលនឹងក្លាយជាកូនសុំនោះផ្ទាល់ នៅក្នុងការសម្រេចចិត្តបង្កើតសុំកូនធម្មតានេះឡើង។ យ៉ាងណាមិញ យើងឃើញថាលក្ខខណ្ឌដែលគេបានកំណត់គឺសំដៅលើ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលនឹងក្លាយជាកូនសុំ។

##### ក.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម

មានលក្ខណៈស្រដៀងគ្នានឹងការបង្កើតសុំកូនពេញលេញដែរ លក្ខខណ្ឌដែលច្បាប់បានកំណត់ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមគឺ លក្ខខណ្ឌអាយុ ការមាន ឬគ្មាន

[24] មាត្រា៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សហព័ទ្ធ និងការយល់ព្រមពីសហព័ទ្ធ (បើមាន) ប៉ុន្តែនៅត្រង់លក្ខខណ្ឌនេះ ច្បាប់មិនបាន កំណត់ថាទាល់តែជនដែលមានសហព័ទ្ធទើបអាចបង្កើតសុំកូនធម្មតាបាននោះទេ។

• **ការមានសហព័ទ្ធ និងការយល់ព្រមពីសហព័ទ្ធ**

ចំពោះការសុំកូនធម្មតា ក៏មិនខុសគ្នាប៉ុន្មានពីការសុំកូនពេញលេញដែរ។ ប៉ុន្តែការសុំកូន ធម្មតា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានកំណត់ឲ្យបានច្បាស់លាស់ថា ជនដែលនឹងក្លាយជា ឪពុក ឬម្តាយចិញ្ចឹម ត្រូវតែមានសហព័ទ្ធនោះទេ។ ដូច្នេះ យើងអាចសន្និដ្ឋានបានថា ជនដែល មានបំណងចង់បង្កើតសុំកូនធម្មតាអាចធ្វើទៅបាន ទោះបីជាខ្លួនមិនមានសហព័ទ្ធក៏ដោយ។

ប៉ុន្តែចំពោះជនដែលមានសហព័ទ្ធ ហើយចង់បង្កើតសុំកូនធម្មតាលើអនីតិជន នោះនៅ ក្នុងការដាក់ពាក្យសុំបង្កើតសុំកូនធម្មតា ត្រូវតែធ្វើឡើងជាមួយសហព័ទ្ធម្ខាងទៀត[25] រួមជាមួយ នឹងអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។ ចំពោះការសុំកូន ធម្មតា ដែលជានីតិជនក្តី ក៏ត្រូវតែមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតដែរ[26]។ យ៉ាងណា មិញ ក្នុងករណីដែលគេយកកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ ឬករណីដែល សហព័ទ្ធម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួននៅក្នុងការដាក់ពាក្យសុំបាននោះ សហព័ទ្ធតែម្ខាង ដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់កូននោះ អាចដាក់ពាក្យសុំបានដោយមិនចាំបាច់ មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ[27]។

• **អាយុ**

ចំពោះអាយុរបស់ជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅ ទើបអាចធ្វើការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាបាន[28]។ យើងឃើញថា ច្បាប់មិន បានកំណត់ពីគម្លាតអាយុរវាងឪពុក ឬម្តាយចិញ្ចឹមនិងកូនសុំឡើយ។ ទោះជាច្បាប់បានកំណត់ អំពីអាយុអប្បបរិមាក៏ដោយ ក៏មិនបានកំណត់ពីអាយុអតិបរិមារបស់ឪពុក ឬម្តាយចិញ្ចឹមដែរ។

យ៉ាងណាមិញ តុលាការគួរតែធ្វើការវិនិច្ឆ័យឱ្យបានល្អិតល្អន់ មុននឹងសម្រេចឱ្យមានការសុំ កូននេះ ទោះបីជាការសុំកូនធម្មតាក្តី ជៀសវាងភាពមិនប្រក្រតីណាមួយអាចកើតឡើង។ គួរគប្បីពិនិត្យមើលអាយុជនដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹម មិនគួរឱ្យមានភាពប្រហែល គ្នា ឬស្មើគ្នានោះឡើយ។

---

[25] មាត្រា១០២១ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[26] មាត្រា១០២២ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[27] មាត្រា១០២១ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[28] មាត្រា១០២០ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**ក.២. លក្ខខណ្ឌចំពោះកូនសុំធម្មតា**

**• អាយុ**

ការសុំកូនធម្មតា មានលក្ខណៈផ្ទុយគ្នាពីការសុំកូនពេញលេញជាច្រើនចំនុច តួយ៉ាងលក្ខខណ្ឌអាយុរបស់កូនសុំនេះ។ នៅក្នុងការបង្កើតសុំកូនធម្មតា ច្បាប់មិនបានកំណត់ពីអាយុរបស់កូនសុំទេ មានន័យថាគេអាចធ្វើការបង្កើតសុំកូនធម្មតាលើក្មេងអាយុប៉ុន្មានក៏បានដែរ។ កូនសុំធម្មតាអាចជានីតិជន ឬអនីតិជន។ ក្នុងក្រមរដ្ឋប្បវេណីក៏ពុំបានចែងអំពីលក្ខខណ្ឌអាយុរបស់កូនសុំ តែបានចែងពីអាយុរបស់ជនដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែ នៅក្នុងក្រមរដ្ឋប្បវេណីបានចែងដែរថា បុគ្គលដែលនឹងក្លាយជាកូនសុំ មិនអាចមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានទេ[29]។

**• ទំនាក់ទំនងញាតិ**

ចំពោះលក្ខខណ្ឌនេះ គេសំដៅលើទំនាក់ទំនងរវាងកូនសុំ និងបុគ្គលដែលជាឪពុកម្តាយចិញ្ចឹម។ តាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានទេ[30]។ ពាក្យថាបុព្វញាតិ តាមសន្ទានុក្រមផ្នែករដ្ឋប្បវេណីមានន័យថា ជនដែលស្ថិតនៅក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួន។ ដូច្នេះ ទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមត្រូវតែជាអ្នកដែលមិនជាប់សាច់ឈាមអ្វីនឹងគ្នា លើកលែងតែករណីដែលសហព័ទ្ធម្ខាងសុំកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនចិញ្ចឹម។

**ក.៣. លក្ខខណ្ឌផ្សេងៗទៀត**

**• ការបង្ហាញឆន្ទៈរបស់ភាគីកូនសុំ**

ជនដែលបង្កើតសុំកូនធម្មតាក្តី សុំកូនពេញលេញក្តី ភាគច្រើនសុទ្ធតែជាជនដែលពុំអាចមានកូនបាន ឬមានបំណងក្នុងការផ្តល់ប្រយោជន៍នានាដល់កូនសុំនោះ។ ដូច្នេះ យើងឃើញថាបុគ្គលដែលមានបំណងដូចខាងលើ ពិតជាមានឆន្ទៈ និងគំនិតសុច្ចរិតក្នុងការបង្កើតសុំកូន។ ប៉ុន្តែចំពោះបុគ្គលខ្លះដែលធ្វើការសុំបង្កើតសុំកូនធម្មតាក្នុងគោលបំណងទុច្ចរិតវិញ គេពុំត្រូវបានទទួលស្គាល់ និងអនុញ្ញាតឡើយ។

ចំពោះការសុំកូនធម្មតានេះ  យើងចែកជាពីរករណី គឺករណីដែលកូនសុំជាអនីតិជន និងនីតិជន។ បើគេធ្វើការសុំកូនជាអនីតិជន គេត្រូវមើលថាការបង្កើតសុំកូននោះ បានផ្តល់ប្រយោជន៍អ្វីខ្លះដល់កូនសុំនោះ ឬមានភាពចាំបាច់ពិសេសណាមួយដែលត្រូវបង្កើតសុំកូននេះ

[29] មាត្រា១០២០ កថាខណ្ឌទី១ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[30] មាត្រា១០២០ កថាខណ្ឌទី១ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ឡើង[31]។ បើកូនសុំនោះជាអនីតិជនដែលមានអាយុដល់១៥ (ដប់ប្រាំ)ឆ្នាំហើយនោះ គេអនុញ្ញាតឱ្យអនីតិជននោះបង្ហាញឆន្ទៈរបស់ខ្លួន ក្នុងការយល់ព្រម ឬមិនយល់ព្រមក្នុងការបង្កើតសុំកូនធម្មតា[32]។ ដោយយោងតាមស្មារតីនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ[33] និងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាអនីតិជននោះមិនទាន់មានអាយុដល់១៥ (ដប់ប្រាំ)ឆ្នាំក៏ដោយ តែអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន នោះតុលាការនឹងអនុញ្ញាតឱ្យអនីតិជននោះធ្វើការបង្ហាញយោបល់របស់ខ្លួន ហើយតុលាការនឹងធ្វើការវិនិច្ឆ័យលើការបង្កើតសុំកូនធម្មតានេះ[34]។

- **លក្ខខណ្ឌវិនិច្ឆ័យ**

យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា តុលាការអាចអនុញ្ញាតឱ្យបង្កើតសុំកូនបាន លុះត្រាតែអាចបញ្ជាក់ពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ តុលាការមិនឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពាន ក្នុងគោលបំណងដើម្បីបានរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងៗគ្នា ឬភេទដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត[35]។

### ខ. លក្ខខណ្ឌទម្រង់

មិនថាតែការសុំកូនពេញលេញទេដែលត្រូវឱ្យបំពេញតាមលក្ខខណ្ឌទម្រង់ ប៉ុន្តែការសុំកូនធម្មតាក៏ត្រូវបំពេញតាមលក្ខខណ្ឌទម្រង់ដែលច្បាប់បានកំណត់ដូចគ្នា។ លក្ខខណ្ឌទម្រង់គឺជានីតិវិធី ឬរបៀបនៃការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាតាមផ្លូវតុលាការ ដើម្បីទទួលបានការវិនិច្ឆ័យ និងសេចក្តីសម្រេចពីតុលាការ។

#### ខ.១. ការដាក់ពាក្យ និងអ្នកមានសិទ្ធិដាក់ពាក្យសុំ

ការដាក់ពាក្យសុំបង្កើតសុំកូនធម្មតា មិនខុសគ្នាពីការសុំកូនពេញលេញទេ គឺអ្នកដែលនឹងក្លាយជាឪពុក ឬម្តាយចិញ្ចឹមត្រូវតែជាអ្នកធ្វើការដាក់ពាក្យសុំទៅតុលាការ ដើម្បីបង្កើតសុំកូន។ ចំពោះការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាលើកូនសុំដែលជានីតិជន បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬឪពុក ឬម្តាយចិញ្ចឹម ត្រូវដាក់ពាក្យសុំទៅតុលាការជាមួយនឹងសហព័ទ្ធ និង

[31] មាត្រា១០២៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[32] មាត្រា១០២៤ កថាខណ្ឌទី៣ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[33] មាត្រា៩ កថាខណ្ឌទី១ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។
[34] មាត្រា១០២៤ កថាខណ្ឌទី៣ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[35] មាត្រា១០២៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កូនសុំដែលជាអនីតិជននោះ[36]។

ចំពោះការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាលើកូនសុំដែលជាអនីតិជនវិញ គេត្រូវដាក់ពាក្យសុំទៅតុលាការជាមួយអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំដែលជាអនីតិជនដូចដែលច្បាប់បានកំណត់[37]។

**ខ.២. ទម្រង់នៃពាក្យសុំ**

ចំពោះទម្រង់នៃពាក្យសុំនេះ មិនមានអ្វីខុសគ្នាពីទម្រង់នៃពាក្យសុំបង្កើតសុំកូនពេញលេញទេ ពោលគឺមានទម្រង់ដូចគ្នា។

**ខ.៣. ស្ថាប័នទទួលពាក្យសុំ**

មានលក្ខណៈខុសគ្នាដាច់ស្រឡះ ចំពោះទីកន្លែងនៃការទទួលពាក្យសុំបង្កើតសុំកូននេះ។ ការដាក់ពាក្យសុំបង្កើតសុំកូនពេញលេញ គឺច្បាប់តម្រូវឱ្យធ្វើឡើងនៅតុលាការដែលស្ថិតនៅលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែចំពោះការដាក់ពាក្យសុំបង្កើតសុំកូនធម្មតាវិញ យោងតាមតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានចែងថា តុលាការដែលមានសមត្ថកិច្ចនៅក្នុងការសម្រេចឱ្យបង្កើតសុំកូនធម្មតាគឺ តុលាការនៃលំនៅឋានរបស់អ្នកដែលក្លាយជាកូនសុំ[38]។

**កថាខណ្ឌទី២ ៖ អានុភាពនៃសុំកូនធម្មតា**

នៅត្រង់ចំណុចនេះ យើងឃើញថាមានភាពខុសគ្នាពីអានុភាពនៃសុំកូនពេញលេញ។ បន្ទាប់ពីទទួលបានសេចក្តីសម្រេចពីតុលាការ ដើម្បីបង្កើតសុំកូនធម្មតាហើយនោះ ច្បាស់ណាស់ថាវានឹងនាំឱ្យមានការបង្កើតញាតិភាពមួយថ្មីជាមួយនឹងឪពុកម្តាយចិញ្ចឹម ប៉ុន្តែចំណុចមួយទៀតនោះគឺ វាមិនបានមានអានុភាពកាត់ផ្តាច់ញាតិភាពជាមួយឪពុកម្តាយបង្កើតទេ កូនសុំនៅតែអាចបន្តញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ខ្លួនដូចដើមដដែល។

**ក. ការបង្កើតញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម**

ជាទូទៅ នៅពេលដែលពាក្យសុំបង្កើតសុំកូនពេញលេញ ក៏ដូចជាសុំកូនធម្មតាមានអានុភាពទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយ ឬឪពុក ឬម្តាយចិញ្ចឹមនឹងកើតឡើងដូចគ្នា។ កូនសុំនោះនឹងក្លាយទៅជាកូនរបស់ឪពុកម្តាយចិញ្ចឹម ជាមួយសិទ្ធិ និងករណីយកិច្ចផ្សេងៗបន្ថែមទៀតដែលពុំធ្លាប់មានពីមុនមកជាមួយឪពុកម្តាយចិញ្ចឹមនោះ។ ជារួម កូនសុំនឹងត្រូវទទួលបានឋានៈ

[36] មាត្រា១០២០ កថាខណ្ឌទី១ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[37] មាត្រា១០២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[38] ចំណុចទី៩ នៃផ្នែកទី៤ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

ដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ និងទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម[39]។ ចំណែកឯ ឪពុកម្តាយ ឬឪពុក ឬម្តាយចិញ្ចឹមក៏ដូចគ្នាដែរ។ ពួកគេនឹងក្លាយជាឪពុកម្តាយពេញសិទ្ធិលើកូនសុំនោះ ហើយមានករណីយកិច្ចចិញ្ចឹមបីបាច់ ថែរក្សាកូននោះ និងផ្តត់ផ្គង់ផ្តល់ផលប្រយោជន៍ដល់កូនសុំនោះដូចជាកូនបង្កើតដែរ។

**ខ. ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត**

ផ្ទុយពីការសុំកូនពេញលេញទាំងស្រុង ការសុំកូនធម្មតាមិនតម្រូវឱ្យកូនសុំផ្តាច់ទំនាក់ទំនងពីឪពុកម្តាយបង្កើត ក៏ដូចជាសាច់ញាតិបង្កើតរបស់គេឡើយ ហើយកូនសុំ និងឪពុកម្តាយបង្កើតនៅតែមានសិទ្ធិក្នុងការធ្វើសន្តតិកម្មគ្នាទៅវិញទៅមកដដែល[40]។ ដូច្នេះយើងអាចសន្និដ្ឋានថា ទោះបីកូនសុំនោះបានបង្កើតទំនាក់ទំនងញាតិមួយថ្មី ជាមួយឪពុកម្តាយចិញ្ចឹមពិតមែនក្តី ក៏ទំនាក់ទំនងរបស់ខ្លួនជាមួយឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុក ម្តាយបង្កើតនោះទាំងឡាយនៅតែរក្សាដូចដើមមិនមានការប្រែប្រួលឡើយ។

[39] មាត្រា១០២៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[40] មាត្រា១០២៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី២

# ការកាត់កាល់ស៊ុំកូន

# ជំពូកទី២

# ការកាត់កាល់សុំកូន

ជាទូទៅ ប្រជាពលរដ្ឋកម្ពុជាតែងតែយល់ថា ពួកគាត់អាចធ្វើការកាត់កាល់កូនៗរបស់គាត់បានគ្រប់គ្នា មិនថាកូននោះជាកូនបង្កើត ឬកូនចិញ្ចឹមនោះទេ។ ប៉ុន្តែយើងឃើញថា នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានកំណត់ការកាត់កាល់កូនជាពីរប្រភេទគឺ ការកាត់កាល់សុំកូនពេញលេញ និងការកាត់កាល់សុំកូនធម្មតា ប៉ុន្តែពុំមានមាត្រាណាមួយបានកំណត់ពីការកាត់កាល់កូនបង្កើតនោះទេ។ អ្វីទៅជាការកាត់កាល់? បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់ថា ការកាត់កាល់គឺជាហេតុនៃការបញ្ចប់ទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលជាហេតុនាំឲ្យមានការកាត់ផ្តាច់ទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ច ដូចជា អាហារកាតព្វកិច្ច[41] និងសន្តតិកម្ម[42]ជាដើម។ [43]

## ផ្នែកទី១ ៖ ការកាត់កាល់សុំកូនពេញលេញ

ដោយសុំកូនពេញលេញ សំដៅដល់ការសុំកូនដែលមានអាយុក្រោម៨ (ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំ ហើយមានអានុភាពបង្កើតទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយចិញ្ចឹម និងកូនសុំ និងបញ្ចប់ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត រួមទាំងញាតិលោហិត។ ដូច្នេះយើងអាចទាញពន្យល់បានថា ការកាត់កាល់សុំកូនពេញលេញ ជាការកាត់ផ្តាច់ញាតិភាពអចិន្ត្រៃយ៍ និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម។ ច្បាប់បានកំណត់ពីមូលហេតុដែលអាចធ្វើការកាត់កាល់ និងអ្នកដែលមានសិទ្ធិនៅក្នុងការកាត់កាល់ រួមទាំងអានុភាពនៃការកាត់កាល់សុំកូនពេញលេញដែរ។

### កថាខណ្ឌទី១ ៖ មូលហេតុនៃការកាត់កាល់

ចំពោះការកាត់កាល់សុំកូននេះ យើងឃើញថាមិនមែនបុគ្គលណាក៏មានសិទ្ធិក្នុងការដាក់ពាក្យកាត់កាល់សុំកូនបានទេ។ ការកាត់កាល់សុំកូនពេញលេញ ត្រូវបានអនុញ្ញាតឲ្យធ្វើឡើងនៅក្នុងករណីពិសេសផ្សេងៗ ឬដើម្បីផលប្រយោជន៍របស់កូនសុំ ដែលតុលាការយល់ឃើញថា វាជាការចាំបាច់ និងសមស្របនៅក្នុងការកាត់កាល់សុំកូនពេញលេញ។ មូលហេតុទាំងនោះរួមមានដូចជា បើមានការធ្វើបាបពីសំណាក់ឪពុកម្តាយចិញ្ចឹមទៅកាន់កូនសុំដោយមូលហេតុណាមួយ ឬ ឪពុក

[41] អាហារកាតព្វកិច្ច៖ កិច្ច ដែលត្រូវបំពេញតាមផ្លូវច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់ប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទំនងញាតិនឹងគ្នា។

[42] សន្តតិកម្ម៖ ការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

[43] មាត្រា៩៨២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ម្តាយចិញ្ចឹមបានបោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ[44]។ និងមូលហេតុមួយទៀតនោះគឺ ក្នុងករណីដែលឪពុកម្តាយបង្កើតមានស្ថានភាពគ្រួសារមួយដែលល្អប្រសើរជាងពីមុន ឬមានជីវភាពធូធារជាងពីមុន ដែលអាចមានលទ្ធភាពនៅក្នុងការគ្រប់គ្រង ថែរក្សាកូននោះដោយខ្លួនឯងវិញដោយសមរម្យបាន[45]។

ដូច្នេះ យើងឃើញថា ក្រមរដ្ឋប្បវេណីបានចែងយ៉ាងច្បាស់អំពីលក្ខខណ្ឌ ដែលអាចនាំឱ្យមានការកាត់កាល់សុំកូនពេញលេញបាន។ ចំណែកឯលក្ខខណ្ឌដទៃទៀត ដែលច្បាប់ពុំបានចែង ឬលក្ខខណ្ឌដែលយើងពុំបានរៀបរាប់ខាងលើ ការកាត់កាល់នឹងមិនត្រូវបានអនុញ្ញាតិឲ្យធ្វើឡើងនោះទេ[46]។

## កថាខណ្ឌទី២ ៖ អ្នកមានសិទ្ធិកាត់កាល់

នៅមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា បុគ្គលដែលមានសិទ្ធិនៅក្នុងការដាក់ពាក្យកាត់កាល់សុំកូនពេញលេញទៅតុលាការ មានដូចជា កូនសុំផ្ទាល់តែម្តង ឪពុកម្តាយបង្កើតរបស់កូនសុំនោះ និងតំណាងអយ្យការ។

### ក. កូនសុំ

ជាទូទៅ កូនសុំជាបុគ្គលម្នាក់ដែលត្រូវទទួលបានផលប្រយោជន៍ពីការបង្កើតសុំកូន ដូចជាការទទួលបានគ្រួសារថ្មីមួយដែលល្អ មានគ្រួសារដែលមានជីវភាពប្រសើរជាងមុន ទទួលបានការថែរក្សា និងបីបាច់ និងទទួលការសិក្សាជាដើម។

ដូចនេះ ដើម្បីធានាឱ្យបាននូវផលប្រយោជន៍របស់កូនសុំ និងជៀសវាងអំពើមិនសមរម្យពីសំណាក់ឪពុកម្តាយចិញ្ចឹមមកលើកូនសុំ តាមក្រមរដ្ឋប្បវេណីបានផ្តល់សិទ្ធិអាទិភាពឱ្យកូនសុំក្នុងការដាក់ពាក្យសុំកាត់កាល់សុំកូនសម្រាប់ខ្លួនបាន។ ពាក្យសុំកាត់កាល់ត្រូវយកទៅដាក់នៅតុលាការ ដើម្បីទទួលបានសេចក្តីសម្រេច។

### ខ. ឪពុកម្តាយបង្កើត

ដោយយោងតាមក្រមរដ្ឋប្បវេណី ឪពុកម្តាយបង្កើតរបស់កូនសុំ ជាបុគ្គលដែលមានសិទ្ធិក្នុងការធ្វើពាក្យបណ្តឹងទៅតុលាការ ដើម្បីកាត់កាល់សុំកូនពេញលេញបានដែរ។ ដោយហេតុថាឪពុកម្តាយជាបុគ្គលដែលមានទំនាក់ទំនងជាមួយកូន និងមានញាតិភាពជាមួយកូននោះ តាំងពីមុនពេលធ្វើការបង្កើតសុំកូនពេញលេញមកម្ល៉េះ។

---

[44] មាត្រា១០១៦ កថាខណ្ឌទី១ (ចំណុច ក) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[45] មាត្រា១០១៦ កថាខណ្ឌទី១ (ចំណុច ខ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[46] មាត្រា១០១៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នៅក្នុងការកាត់កាល់នេះ ឪពុកម្ដាយបង្កើតរបស់កូនសុំអាចធ្វើការកាត់កាល់សុំកូនពេញលេញបាន លុះត្រាតែយោងតាមលក្ខខណ្ឌដែលបានកំណត់នៅចំណុចខាងលើ។ ករណីដែលឪពុកម្ដាយបង្កើតមានជីវភាពធូរធាជាងកាលពីមុន ឬមានស្ថានភាពគ្រួសារមួយដែលល្អប្រសើរសម្រាប់កូននោះ នោះតុលាការនឹងផ្ដល់សិទ្ធិឱ្យឪពុកម្ដាយបង្កើត ដើម្បីប្ដឹងកាត់កាល់សុំកូនពេញលេញ ហើយយកកូននោះទៅចិញ្ចឹមបីបាច់ថែរក្សាដោយផ្ទាល់វិញបាន។

**គ. តំណាងអយ្យការ**

បុគ្គលចុងក្រោយ ដែលច្បាប់បានកំណត់ថាជាជនដែលមានសិទ្ធិក្នុងការកាត់កាល់សុំកូនពេញលេញគឺ តំណាងអយ្យការ។ តំណាងអយ្យការ គឺជាអ្នកដែលមានសិទ្ធិក្នុងការការពារផលប្រយោជន៍សាធារណៈ នៅក្នុងនីតិវិធីតុលាការ។ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថា ពាក្យបណ្ដឹងត្រូវបានទទួល ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ[47]។ យ៉ាងណាមិញ ទោះជាគ្មានការជូនដំណឹងពីតុលាការក៏ដោយ ក៏តំណាងអយ្យការអាចធ្វើការចូលរួមនៅក្នុងនីតិវិធីតុលាការ និងបញ្ចេញមតិរបស់ខ្លួនបាន បើមានគោលបំណង ដើម្បីការពារផលប្រយោជន៍សាធារណៈ[48]។ ជាក់ស្ដែង ករណីដែលភាគីកូនសុំជាអនីតិជន ឬភាគីឪពុកម្ដាយបង្កើតបានទទួលមរណៈភាព ឬហេតុផលផ្សេងៗទៀតទាក់ទងនឹងការប្រើប្រាស់អំពើហិង្សាលើកូនសុំជាដើម ដែលសុទ្ធតែជាបញ្ហាដែលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ នោះតំណាងអយ្យការអាចជាអ្នកមានតួនាទីក្នុងការដាក់ពាក្យសុំកាត់កាល់កូនទៅតុលាការបាន។

**កថាខណ្ឌទី៣ ៖ អានុភាពនៃការកាត់កាល់សុំកូនពេញលេញ**

ការសុំកូនពេញលេញ ប្រៀបដូចទៅនឹងកិច្ចសន្យាមួយដូច្នោះដែរ។ នៅពេលដែលកិច្ចសន្យាសុំកូននេះត្រូវបានបញ្ចប់ ដោយការកាត់កាល់សុំកូនពេញលេញ វាបណ្ដាលឱ្យមានអានុភាពផ្លូវច្បាប់ចំពោះភាគីទាំងអស់នៃសុំកូន។ យើងអាចនិយាយបានថា អានុភាពនៃការកាត់កាល់សុំកូនពេញលេញមានលក្ខណៈប្រតិសកម្ម ព្រោះតាមរយៈអានុភាពរបស់វា នឹងធ្វើឲ្យអានុភាពនៃសុំកូនពេញលេញត្រូវបានបញ្ចប់ ហើយអ្វីៗនឹងត្រលប់ទៅសភាពដើមវិញ។

ញាតិភាពរវាងកូនសុំពេញលេញ និងឪពុកម្ដាយចិញ្ចឹមត្រូវបានកាត់ផ្ដាច់ និងក្លាយជាអ្នកដទៃដោយគ្មានជាប់ទំនាក់ទំនង និងករណីយកិច្ចរវាងគ្នាទៅវិញទៅមកទៀតឡើយ។ ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ ពុំបានចែងពីការប្រើប្រាស់នាមត្រកូលរបស់កូនសុំ

[47] មាត្រា៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[48] មាត្រា៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឡើយ ថាអាចបន្តប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬត្រូវប្តូរទៅនាមត្រកូលមុនពេលបង្កើតសុំកូនពេញលេញវិញឬយ៉ាងណា។

ក្រៅពីបញ្ចប់ញាតិភាពជាមួយឪពុកម្តាយចិញ្ចឹមហើយ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត រួមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូនពេញលេញ ក៏ត្រូវកើតឡើងវិញគិតចាប់ពីថ្ងៃកាត់កាល់សុំកូនពេញលេញនេះ [49]។

## ផ្នែកទី២ ៖ ការកាត់កាល់សុំកូនធម្មតា

ចំពោះការកាត់កាល់សុំកូនធម្មតា មានលក្ខណៈខុសគ្នាបន្តិចពីការកាត់កាល់សុំកូនពេញលេញដែលយើងបានរៀបរាប់រួចមកហើយ។ ដោយការកាត់កាល់សុំកូនធម្មតា ចែកចេញជាពីរផ្នែកធំៗ គឺការកាត់កាល់ដោយមានការព្រមព្រៀងគ្នារវាងភាគីសុំកូន និងការកាត់កាល់ដែលកំណត់ដោយច្បាប់។ លើសពីនេះទៅទៀត ការកាត់កាល់សុំកូនធម្មតាដោយការព្រមព្រៀងគ្នា បែងចែកជាពីរទៀត គឺក្នុងករណីដែលកូនសុំជានីតិជន និងក្នុងករណីដែលកូនសុំជាអនីតិជន។

### កថាខណ្ឌទី១ ៖ ការកាត់កាល់ដោយមានការព្រមព្រៀងគ្នា

ការកាត់កាល់ដោយមានការព្រមព្រៀងគ្នា គឺសំដៅលើការព្រមព្រៀងរវាងភាគីសុំកូន។ បើយើងនិយាយពីភាគីសុំកូន យើងអាចយល់បានថាសំដៅលើឪពុកម្តាយចិញ្ចឹម និងកូនសុំផ្ទាល់តែម្តង។ ប៉ុន្តែដោយសារតែការកាត់កាល់ដោយមានការព្រមព្រៀងនេះ អាចធ្វើឡើងចំពោះកូនសុំដែលជានីតិជន និងអនីតិជន ដូច្នេះភាគីមួយទៀតដែលជាអ្នកមានសិទ្ធិក្លាយជាភាគីនៃការកាត់កាល់នេះបាន គឺអ្នកតំណាងកូនសុំជាអនីតិជនដែលច្បាប់បានកំណត់។

#### ក. កូនសុំជានីតិជន

តាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បុគ្គលដែលបានក្លាយជានីតិជន ជាបុគ្គលដែលមានសមត្ថភាពក្នុងការយល់ដឹងពីលទ្ធភាពនៃអំពើរបស់ខ្លួន ដូចជាការសម្រេចចិត្តក្នុងការធ្វើអ្វីមួយដោយខ្លួនឯង ដោយមិនចាំបាច់មានការយល់ព្រមពីអាណាព្យាបាលជាដើម។ គេអាចមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិសម្រេចចិត្តក្នុងការចុះកិច្ចសន្យាផ្សេងៗបាន តួយ៉ាងដូចជាការសម្រេចចិត្តក្នុងការដាក់ពាក្យសុំកាត់កាល់សុំកូនធម្មតា។

ក្នុងករណីដែលកូនសុំជានីតិជនបែបនេះ គេអាចមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ទៅតុលាការដោយខ្លួនឯងផ្ទាល់បាន ហើយភាគីឪពុកម្តាយចិញ្ចឹមក៏មានសិទ្ធិដាក់ពាក្យសុំកាត់កាល់បានដែរ

[49] មាត្រា១០១៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ពោលគឺភាគីទាំងសងខាងសុទ្ធតែជាអ្នកមានសិទ្ធិដាក់ពាក្យសុំកាត់កាល់[50]។ ប៉ុន្តែមុននឹងសម្រេចឱ្យមានការកាត់កាល់នេះបាន តុលាការត្រូវពិនិត្យឱ្យបានច្បាស់លាស់ថាវាពិតជាធ្វើឡើងដោយគោលបំណង និងការព្រមព្រៀងគ្នាហើយនោះរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមក្នុងការរំលាយទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមនេះ[51]។

**ខ. កូនសុំជាអនីតិជន**

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ អនីតិជន សំដៅលើជនដែលមានអាយុក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ ហើយអនីតិជនពុំអាចមានសមត្ថភាពក្នុងការដាក់ពាក្យសុំបានឡើយ ព្រោះច្បាប់បានកំណត់ជាទូទៅថា អនីតិជនជាជនដែលពុំទាន់មានលទ្ធភាពក្នុងការបង្ហាញឆន្ទៈរបស់ខ្លួនឡើយ។ ដោយសារតែករណីនេះ កូនសុំមិនអាចក្លាយជាភាគី នៅក្នុងការដាក់ពាក្យសុំកាត់កាល់នេះបាន ទើបច្បាប់បានកំណត់ពីអ្នកតំណាងសម្រាប់កូនសុំជាអនីតិជន។

អ្នកដែលអាចដាក់ពាក្យសុំកាត់កាល់ស្មុំកូនធម្មតាបានគឺ ឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពីពេលកាត់កាល់[52]។ ក្នុងករណីដែលឪពុកម្តាយចិញ្ចឹមបានសហការគ្នាដាក់ពាក្យសុំបង្កើតស្មុំកូនដែលជាអនីតិជន នោះដើម្បីធ្វើការកាត់កាល់ស្មុំកូននោះវិញ សហព័ទ្ធទាំងពីរដែលជាឪពុកម្តាយចិញ្ចឹមត្រូវធ្វើការដាក់ពាក្យសុំកាត់កាល់រួមគ្នាទៅតុលាការ ជាមួយភាគីម្ខាងទៀត។ ប៉ុន្តែ ចំពោះករណីដែលមានសហព័ទ្ធណាម្ខាងមិនអាចធ្វើការបង្ហាញឆន្ទៈបាននោះ សហព័ទ្ធតែម្ខាងក៏អាចដាក់ពាក្យសុំកាត់កាល់ទៅតុលាការបានដែរ។[53]

អ្នកតំណាងរបស់កូនសុំ ជាទូទៅអាចជាឪពុកម្តាយបង្កើតរបស់កូននោះតែម្តង។ ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនសុំបានលែងលះគ្នាហើយ នោះឪពុកម្តាយបង្កើតអាចធ្វើការពិភាក្សាគ្នា ដើម្បីសម្រេចពីអ្នកដែលនឹងក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់[54]។ ប៉ុន្តែ បើការពិភាក្សាគ្នារវាងឪពុកម្តាយបង្កើតនោះ ពុំបានសម្រេច ឬពួកគាត់មិនអាចពិភាក្សាគ្នាបានទេ តុលាការត្រូវធ្វើការសម្រេចតែម្តង ថាអ្នកណាជាអ្នកមានអំណាចមេបាលើកូនសុំនោះក្រោយពេលកាត់កាល់ ដោយធ្វើការពិចារណាលើផលប្រយោជន៍របស់កូនសុំ

---

[50] មាត្រា១០២៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[51] មាត្រា១០៣០ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[52] មាត្រា១០២៨ កថាខណ្ឌទី២ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[53] មាត្រា១០២៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[54] មាត្រា១០២៨ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នោះជាមុន[55]។ យ៉ាងណាមិញ ទោះជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ជាឪពុកម្ដាយចិញ្ចឹម និងអ្នកតំណាងដែលច្បាប់បានកំណត់ ចំពោះករណីដែលកូនសុំជាអនីតិជនដែលមិនទាន់មានអាយុគ្រប់១៥ (ដប់ប្រាំ)ឆ្នាំក៏ដោយក្ដី ប៉ុន្តែបើគេអាចបង្ហាញឆន្ទៈរបស់ខ្លួនបាននោះ តុលាការត្រូវធ្វើការសួរយោបល់កូនសុំនោះជាមុន មុននឹងសម្រេចឲ្យមានការកាត់កាល់ស៊ុំកូនធម្មតានេះបាន[56]។

**គ. ពាក្យសុំកាត់កាល់**

នៅពេលដែលគេចង់បង្កើតស៊ុំកូនពេញលេញ ឬស៊ុំកូនធម្មតា គេត្រូវដាក់ពាក្យសុំបង្កើតស៊ុំកូនទៅតុលាការ ដើម្បីទទួលបានសេចក្ដីសម្រេច និងធ្វើឲ្យការស៊ុំកូននោះមានអានុភាពតាមផ្លូវច្បាប់។ ដូចគ្នាដែរ នៅពេលដែលភាគីស៊ុំកូនធ្វើការព្រមព្រៀងគ្នាក្នុងការកាត់កាល់ស៊ុំកូនធម្មតាហើយនោះ ភាគីទាំងសងខាងត្រូវដាក់ពាក្យសុំទៅតុលាការដូចគ្នា ដើម្បីកាត់ផ្ដាច់ញាតិភាពដែលបានបង្កើតឡើងកាលពេលមុននោះ។ ឯការដាក់ពាក្យសុំនេះត្រូវដាក់នៅតុលាការនៃលំនៅឋានរបស់កូនសុំ[57]។ ចំនែកឯទម្រង់នៃពាក្យសុំកាត់កាល់[58]នេះ គឺមានទម្រង់ដូចគ្នានឹងពាក្យសុំបង្កើតស៊ុំកូនដែរ។

**កថាខណ្ឌទី២ ៖ ការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់**

ក្រៅពីការកាត់កាល់ដោយព្រមព្រៀងគ្នារវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ ឬអ្នកតំណាងដោយច្បាប់ខាងលើនេះ ការកាត់កាល់ស៊ុំកូនធម្មតាអាចធ្វើឡើងតាមរបៀបមួយទៀត គឺការកាត់កាល់តាមមូលហេតុដែលច្បាប់បានកំណត់។ ការកាត់កាល់តាមរបៀបនេះ អាចធ្វើទៅបានលុះត្រាតែមានមូលហេតុដូចនឹងអ្វីដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើពុំដូច្នោះទេ ភាគីនីមួយៗមិនអាចធ្វើការកាត់កាល់បានទេ។ មូលហេតុទាំងនោះរួមមានដូចជា[59]៖

- បើភាគីណាម្ខាងនៃស៊ុំកូន ត្រូវបានបោះបង់ចោលពីភាគីម្ខាងទៀតដោយពុំមានការផ្ដល់ដំណឹងទាល់តែសោះ។ ម្យ៉ាងវិញទៀត ការបោះបង់ចោលនោះ ជាទង្វើដែលធ្វើឡើងក្នុងគោលបំណងទុច្ចរិតនៃភាគីម្ខាងទៀត។
- បើមានការបាត់ដំណឹងពីភាគីម្ខាង ដោយគ្មានការប្រាប់មុន ក្នុងអំឡុងពេលយ៉ាងតិច១

[55] មាត្រា១០២៨ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[56] មាត្រា១០២៨ កថាខណ្ឌទី២ (វាក្យខណ្ឌ៣) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[57] ចំណុចទី១០ នៃផ្នែកទី៤ នៃតារាងឧបសម្ព័ន្ធនៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។
[58] មាត្រា២៦ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។
[59] មាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

(មួយ)ឆ្នាំ ដែលភាគីម្ខាងទៀតមិនបានដឹងថាតើភាគីនោះបានស្លាប់ ឬនៅរស់រានមានជីវិតនៅឡើយ។ ដូច្នេះ ភាគីណាដែលមិនបានទទួលដំណឹងពីភាគីម្ខាងទៀតនោះ អាចដាក់ពាក្យបណ្តឹងកាត់កាល់ទៅតុលាការបាន។

- ហេតុផលមួយទៀត ដែលអាចនាំឱ្យភាគីនៃស្មុំកូនអាចធ្វើការកាត់កាល់បាននោះ គឺហេតុផលធ្ងន់ធ្ងរផ្សេងៗ ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តទំនាក់ទំនងរបស់ខ្លួន។ ហេតុផលទាំងនោះអាចជា ភាគីកូនសុំជាបុគ្គលដែលមិនស្តាប់ដំបូន្មានឪពុកម្តាយចិញ្ចឹម ឬភាគីណាម្ខាងនៃស្មុំកូនបានទទួលរងអំពើហិង្សា ការបំពាន ឬការធ្វើទារុណកម្មជាដើម ដែលជាហេតុនាំឱ្យភាគីទាំងពីរមិនអាចរស់នៅដោយភាពចុះសម្រុងគ្នាបាន។

**ក. អ្នកមានសិទ្ធិកាត់កាល់**

នៅក្នុងការកាត់កាល់ស្មុំកូនធម្មតា ដោយមូលហេតុដែលកំណត់ដោយច្បាប់ បុគ្គលដែលមានសិទ្ធិអាចកាត់កាល់បានមានចែកជា២ (ពីរ) គឺអ្នកដែលមានសិទ្ធិកាត់កាល់ក្នុងករណីកូនសុំជានីតិជន និងមួយទៀតគឺក្នុងករណីដែលកូនសុំជាអនីតិជន។

ក្នុងករណីដែលកូនសុំជានីតិជន កូនសុំនោះអាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ស្មុំកូនធម្មតាទៅតុលាការដោយផ្ទាល់តែម្តង។ មួយវិញទៀត ឪពុកម្តាយចិញ្ចឹមរបស់កូនសុំនោះ ក៏អាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ទៅតុលការបានដែរ បើមានមូលហេតុច្បាស់លាស់ដូចបានរៀបរាប់ខាងលើ[60]។ ដូច្នេះមានន័យ ទាំងភាគីកូនសុំ និងភាគីឪពុកម្តាយចិញ្ចឹម សុទ្ធតែជាអ្នកមានសិទ្ធិដាក់ពាក្យបណ្តឹងកាត់កាល់ទៅតុលាការ ដោយយោងតាមមូលហេតុដែលច្បាប់បានកំណត់។

មួយវិញទៀត ចំពោះករណីដែលកូនសុំជាអនីតិជនវិញ ច្បាប់មិនបានអនុញ្ញាតឱ្យភាគីឪពុកម្តាយចិញ្ចឹមមានសិទ្ធដាក់ពាក្យបណ្តឹងកាត់កាល់ស្មុំកូនធម្មតាទៅតុលាការបានទេ ទោះជាយោងតាមមូលហេតុដែលបានកំណត់ខាងលើនេះក៏ដោយ[61]។ ការកំណត់បែបនេះ ព្រោះតែគេចង់ការពារផលប្រយោជន៍របស់កូនសុំ ព្រោះថាកូនសុំដែលជាអនីតិជនត្រូវចាត់ទុកជាបុគ្គលដែលពុំទាន់មានលទ្ធភាពអាចយល់ដឹងខ្ពស់ និងអាចពិចារណាពីអំពើដែលខ្លួនបានធ្វើនោះទេ។ ផ្ទុយទៅវិញ ច្បាប់បានអនុញ្ញាតឲ្យភាគីកូនសុំដែលអនីតិជនអាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ទៅតុលាការបាន ដោយយោងតាមមូលហេតុដែលច្បាប់បានកំណត់ខាងលើដូចជា ត្រូវបានបោះបង់ចោលដោយគំនិតទុច្ចរិត ការបាត់ដំណឹងពីភាគីឪពុកម្តាយចិញ្ចឹម និងមូលហេតុធ្ងន់ធ្ងរផ្សេងៗទៀត។ អ្នកតំណាងរបស់កូនសុំដែលកំណត់ដោយច្បាប់ ក៏អាចដាក់ពាក្យបណ្តឹង

[60] ចំនុច ខ «ការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់»។

[61] មាត្រា១០៣១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

កាត់កាល់បានដែរ ប៉ុន្តែបើក្នុងករណីដែលកូនសុំមានអាយុដល់១៥ (ដប់ប្រាំ)ឆ្នាំហើយ នោះគេត្រូវសួរយោបល់របស់កូនសុំនោះជាមុនសិន។ ម្យ៉ាងទៀត ក្នុងករណីកូនសុំជាអនីតិជន ហើយគ្មានឪពុកម្ដាយបង្កើត តំណាងអយ្យការក៏ជាបុគ្គលម្នាក់ដែលអាចតំណាងឲ្យកូនសុំក្នុងការដាក់ពាក្យបណ្ដឹងកាត់កាល់ស្មុំកូនធម្មតាបានដែរ។

**ខ. ពាក្យបណ្ដឹងកាត់កាល់**

ដូចដែលយើងបានបញ្ជាក់ខាងលើថា ការកាត់កាល់ស្មុំកូនធម្មតាចែកចេញជាពីរបែបគឺ ការកាត់កាល់តាមការព្រមព្រៀងគ្នា និងការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់។ ចំពោះការកាត់កាល់ដោយការព្រមព្រៀងគ្នារវាងភាគីស្មុំកូន គឺគេត្រូវដាក់ពាក្យសុំកាត់កាល់ទៅតុលាការ ប៉ុន្តែចំពោះការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់វិញ យោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គេមិនធ្វើការដាក់ពាក្យសុំទេ ប៉ុន្តែភាគីដែលមានសិទ្ធធ្វើការកាត់កាល់ ត្រូវដាក់ពាក្យបណ្ដឹងទៅតុលាការខាងលំនៅឋានរបស់កូនសុំ ដើម្បីកាត់កាល់ស្មុំកូនធម្មតា។

ការប្ដឹង[62]មានលក្ខណៈខុសគ្នាពីការដាក់ពាក្យសុំទៅតុលាការ ហើយទម្រង់នៃពាក្យបណ្ដឹងក៏មានលក្ខណៈខុសគ្នាពីទម្រង់នៃពាក្យសុំដែរ។ ដូច្នេះយើងគប្បីសិក្សាពីរបៀបដាក់ពាក្យបណ្ដឹង និងចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង។ ច្បាប់បានបញ្ញត្តិថា ការដាក់ពាក្យបណ្ដឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតុលាការ[63]។

នៅក្នុងលិខិតនៃពាក្យបណ្ដឹងដែលដាក់ទៅតុលាការ ត្រូវសរសេរបញ្ជាក់ពីចំណុចដែលច្បាប់បានកំណត់ដូចជា៖

១. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

២. ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឲ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់ពីការទាមទារ។ [64]

ក្រៅពីចំណុចដែលត្រូវសរសេរខាងលើនេះ នៅមានចំណុចខ្លះទៀតដែលដើមចោទគប្បីសរសេរនៅក្នុងពាក្យបណ្ដឹងដូចជា បញ្ជាក់ឲ្យបានច្បាស់លាស់ពី អង្គហេតុដែលជាមូលហេតុនៃ

[62] ការប្ដឹង៖ ជាសកម្មភាពមួយដែលទាមទារឲ្យមានការបំពេញលក្ខខណ្ឌជាក់លាក់មួយជាកំណត់ គឺការប្រគល់ពាក្យបណ្ដឹង (ដែលជាសកម្មភាពដែលតម្រូវឲ្យមានលក្ខខណ្ឌទម្រង់) ដើម្បីបង្ហាប់ឲ្យបានច្បាស់លាស់នូវអង្គហេតុនៃការធ្វើបណ្ដឹងតាមនីតិវិធី។

[63] មាត្រា៧៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[64] មាត្រា៧៥ កថាខណ្ឌទី២ (ចំណុចក&ខ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ការទាមទារ[65] និងតាមចំណុចដែលត្រូវបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់អង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង[66]។

**កថាខណ្ឌទី៣ ៖ អានុភាពនៃការកាត់កាល់សុំកូនធម្មតា**

នៅពេលដែលភាគីនីមួយៗដាក់ពាក្យសុំ ឬពាក្យបណ្តឹងកាត់កាល់សុំកូនធម្មតាទៅតុលាការ នោះតុលាការនឹងធ្វើការវិនិច្ឆ័យទៅលើហេតុផលសមរម្យនានាដែលភាគីនីមួយៗបានលើកជូនតុលាការ។ បើសិនជាហេតុផលទាំងនោះ ពិតជាសមរម្យអាចទទួលយកបាន នោះតុលាការនឹងចេញសេចក្តីសម្រេចឱ្យមានការកាត់កាល់សុំកូនធម្មតា។

ក្រោយពីទទួលបានសេចក្តីសម្រេចពីតុលាការឱ្យកាត់កាល់សុំកូនធម្មតា នោះវានឹងបង្កើតអានុភាពតាមផ្លូវច្បាប់។ អ្វីទៅជាអានុភាពនៃការកាត់កាល់សុំកូនធម្មតា? អានុភាពនៃការកាត់កាល់សុំកូនធម្មតា ជាអានុភាពមិនប្រតិសកម្ម មានន័យថា តាមរយៈការកាត់កាល់សុំកូនធម្មតា នាំឱ្យអានុភាពទាំងឡាយដែលបានកើតឡើងនៅពេលបង្កើតសុំកូនធម្មតា ត្រូវបញ្ចប់ចាប់ពីពេលនេះឆ្ពោះទៅអនាគត[67]។ អានុភាពដែលត្រូវបញ្ចប់នោះរួមមានដូចជា ញាតិភាព និង សិទ្ធិ និងករណីយកិច្ចរវាងកូនសុំធម្មតា និងឪពុកម្តាយចិញ្ចឹមរួមទាំងញាតិលោហិតរបស់ឪពុក ម្តាយចិញ្ចឹមនោះដែរ។ល។

យ៉ាងណាមិញ នៅក្រោយពេលកាត់កាល់ កូនសុំនោះអាចប្រើប្រាស់នាមត្រកូលរបស់ខ្លួនដែលមាននៅមុនពេលបង្កើតសុំកូនធម្មតាក៏បាន ឬក៏នៅតែអាចបន្តប្រើប្រាស់នាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បានដែរ[68]។

---

[65] អង្គហេតុដែលជាមូលហេតុនៃការទាមទារៈ ជាអង្គហេតុចាំបាច់សម្រាប់បញ្ជាក់ (បង្ហាញ) អំពីការអះអាងពីសិទ្ធិ ស្មើនឹងការទាមទារតាមផ្លូវបណ្តឹង ដែលដើមចោទទាមទារឲ្យតុលាការធ្វើការជំនុំជម្រះ និងចេញសាលក្រមនៃបណ្តឹងនេះ ដើម្បីកុំឲ្យមានការភាន់ច្រឡំ និងការមិនអាចបែងចែកបានទៅនឹងការទាមទារផ្សេងទៀត រួមជាមួយនឹងការសរសេរអំពីសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ។

[66] មាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[67] មាត្រា១០៣២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[68] មាត្រា១០៣២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី៣
# សិទ្ធិរបស់កូនសុំ

# ជំពូកទី៣

# សិទ្ធិរបស់កូនសុំ

មនុស្សម្នាក់ៗដែលកើតមក តែងតែមានសិទ្ធិរបស់ខ្លួនដែលអាចហៅបានថា បុគ្គលភាពគតិយុត្ត។ សិទ្ធិទាំងនោះមានលក្ខណៈផ្សេងៗ ទៅតាមតួនាទី និងឋានៈរបស់យើង។ ចំពោះកូនៗ ក៏ដូចគ្នា ក្នុងនាមជាកូន តើពួកគេមានសិទ្ធិអ្វីខ្លះ? យើងឃើញថា តាមការបកស្រាយខាងលើ ការសុំកូនមានពីរបែបគឺ ការសុំកូនពេញលេញ និងការសុំកូនធម្មតា ដូច្នេះតើកូនសុំទាំងពីរប្រភេទនេះមានសិទ្ធិយ៉ាងណា? យោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ សិទ្ធិដែលកូនសុំទទួលបាន គឺដូចគ្នាទៅនឹងសិទ្ធិរបស់កូនបង្កើតនៃឪពុកម្ដាយចិញ្ចឹមនោះដែរ មានន័យថា ទោះជាកូននោះជាកូនបង្កើតក្ដី ឬកូនចិញ្ចឹមក្ដីគឺត្រូវទទួលបានសិទ្ធិក្នុងនាមជាកូនដូចគ្នា។ ដូច្នេះសិទ្ធិរបស់កូនៗ មិនថាកូននោះជាអនីតិជន ឬនីតិជន គឺច្បាប់បានកំណត់ផ្ដល់ឲ្យនូវសិទ្ធិជាច្រើនដូចជាសិទ្ធិរៀបអាពាហ៍ពិពាហ៍ សិទ្ធិចុះកិច្ចសន្យា (ចំពោះនីតិជន)។ ហេតុនេះហើយ យើងនឹងមិនលើកយកសិទ្ធិទាំងអស់នោះមកបកស្រាយនោះទេ យើងយកតែសិទ្ធិសំខាន់ៗ ដែលកូនសុំអាចទទួលបានពីការបង្កើតសុំកូនមកធ្វើការបកស្រាយតែប៉ុណ្ណោះ។

## ផ្នែកទី១ ៖ សិទ្ធិរបស់កូនសុំពេញលេញ

### ក. សិទ្ធិទទួលដឹងពីកំណើត

ទោះបីជាយើងបានធ្វើការបកស្រាយខាងលើថា ការសុំកូនពេញលេញជាការសុំកូនតាមផ្លូវច្បាប់ដោយធ្វើឡើងតាមលំហូរនីតិវិធីច្បាប់ ហើយការសុំកូននេះតម្រូវឲ្យកូនសុំផ្ដាច់ទំនាក់ទំនងញាតិភាពពីឪពុកម្ដាយបង្កើត និងញាតិលោហិតរបស់ឪពុកម្ដាយបង្កើត ប៉ុន្តែកូនសុំនោះនៅតែមានសិទ្ធិដឹងពីកំណើតរបស់ខ្លួនជានិច្ច នៅពេលដែលខ្លួនបានក្លាយជានីតិជន ព្រោះថា នៅពេលដែលមានការសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ប៉ុន្តែនៅក្នុងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្រកំណើត ឬឯកសារដកស្រង់នៃបញ្ជីកំណើត មិនបានសរសេរចំណុចស្ដីពីសុំកូនឡើយ[69]។

ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងថា កូនសុំពេញលេញដែលបានក្លាយជានីតិជនអាចទាមទារឱ្យបង្ហាញពតិមានក្នុងទំហំដែលចាំបាច់ចំពោះតុលាការដែលរក្សាទុកសំណុំរឿងស្ដីពីសុំកូនបាន[70]។ ប៉ុន្តែក្នុងករណីដែលកូនសុំនោះមានបំណងទុច្ចរិត គេអាចបដិសេធមិនធ្វើ

---

[69] មាត្រា១០១៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[70] មាត្រា១០១៩ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

តាមការទាមទារសុំនោះបាន[71]។

**ខ. សិទ្ធិប្រើប្រាស់នាមត្រកូលដែលពេញចិត្ត**

នៅពេលសុំកូនមានអានុភាព កូនសុំនឹងក្លាយជាកូនពេញសិទ្ធិរបស់ឪពុកម្ដាយចិញ្ចឹមនោះ ហើយមានឋានៈដូចកូនបង្កើតដែរ[72]។ នៅក្នុងការប្រប្រាស់នាមត្រកូលវិញ យើងឃើញថាកូនៗភាគច្រើន គឺយកនាមត្រកូលតាមឪពុកម្ដាយ ហើយការដាក់នាមត្រកូលរបស់កូន ជាទូទៅគេធ្វើឡើងតាំងពីថ្ងៃដែលកូននោះទើបតែកើតមកម្ល៉េះ។ ដូច្នេះ យើងអាចទាញពន្យល់បានថា កូនសុំនោះប្រាកដជាមាននាមត្រកូលរបស់ខ្លួន មុនពេលបង្កើតសុំកូនទៅទៀត។ ដូច្នេះ ទើបបន្ទាប់ពីបង្កើតការសុំកូនរួច គេអាចផ្ដល់ជម្រើសដល់កូនសុំនោះក្នុងការប្រើប្រាស់នាមត្រកូលថ្មីរបស់ឪពុកម្ដាយចិញ្ចឹម ឬប្រើប្រាស់នាមត្រកូលនៅមុនពេលសុំកូនរបស់ខ្លួនបាន[73]។

ប៉ុន្តែ ក្នុងករណីដែលកូននោះជាកូនដែលគេរើសបាន ហើយគ្មាននាមត្រកូល នៅក្រោយពេលបង្កើតសុំកូន កូននោះត្រូវប្រើប្រាស់នាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមនោះជាដាច់ខាត។

**គ. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម**

អំណាចមេបា ជាសិទ្ធិ និងករណីយកិច្ចក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ[74]។

ជាទូទៅ កូនគ្រប់រូបដែលជាអនីតិជនត្រូវស្ថិតក្រោមការគ្រប់គ្រង និងថែរក្សារបស់ឪពុកម្ដាយ ឬអ្នកមានអំណាចមេបារបស់កូននោះតាមផ្លូវច្បាប់។ ដោយឡែក ចំពោះករណីកូនសុំវិញ នៅពេលដែលការសុំកូនពេញលេញមានអានុភាពហើយនោះ កូនសុំនឹងត្រូវបញ្ចប់ញាតិភាពរវាងខ្លួន និងឪពុកម្ដាយបង្កើត ហើយបង្កើតញាតិភាពថ្មីជាមួយឪពុកម្ដាយចិញ្ចឹមវិញ។ ដូច្នេះ កូនសុំមិនត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយបង្កើតទៀតទេ។ កូនសុំដែលនៅតែជាអនីតិជនត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹមវិញ[75] ។

យ៉ាងណាមិញ ចំពោះករណីដែលប្ដីប្រពន្ធណាម្ខាងក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្ដាយបង្កើត និងឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម[76]។

[71] មាត្រា១០១៩ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[72] មាត្រា១០១៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[73] មាត្រា១០១៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[74] មាត្រា១០៣៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[75] មាត្រា១០១៥ កថាខណ្ឌទី៣ (វាក្យខណ្ឌ១) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។
[76] មាត្រា១០១៥ កថាខណ្ឌទី៣ (វាក្យខណ្ឌ២) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ឃ. សិទ្ធិទទួលបានអាហារកាតព្វកិច្ច

ពាក្យថា «អាហារកាតព្វកិច្ច» ដោយយោងតាមសន្ធានុក្រមផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យថា ជាកិច្ចដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិជាមួយគ្នា។

ដូច្នេះ មានន័យថា កូនគ្រប់រូប ទោះជាកូនបង្កើតក្តី ឬកូនសុំក្តី ត្រូវតែទទួលបានការផ្គត់ផ្គង់ពីឪពុកម្តាយ តាមរយៈប្រាក់ ឬទ្រព្យសម្បត្តិនានា សម្រាប់ការរស់នៅប្រចាំថ្ងៃ និងការសិក្សារៀនសូត្រជាដើម។

### ង. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម

ការធ្វើសន្តតិកម្ម គឺជាការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជន ទៅឱ្យសន្តតិជន[77]ម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់ (សន្ធានុក្រមផ្នែករដ្ឋប្បវេណី)។ ក្រោយពីបង្កើតសុំកូនពេញលេញ កូនសុំទទួលបានសិទ្ធិដូចកូនបង្កើត ហើយក្នុងនោះក៏មានសិទ្ធិធ្វើ និងទទួលសន្តតិកម្មដែរ។ ដូច្នេះ កូនសុំ និងឪពុកម្តាយចិញ្ចឹមមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក ហើយញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមក៏អាចមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមកនឹងកូនសុំបានដែរ។

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ កូនរបស់មតកជន ត្រូវក្លាយជាសន្តតិជនលំដាប់ទី១ ជានិច្ច[78]។ ជារួមគឺ កូនៗរបស់មតកជនមានសិទ្ធិក្លាយជាសន្តតិជនលំដាប់ទី១ ជានិច្ច បើពុំមានបញ្ហាអ្វីកើតឡើងទេ។ ការបែងចែកមិតករបស់មតកជនចំពោះសន្តតិជនលំដាប់ទី១ ពោលគឺកូនៗនេះ ត្រូវចែកឱ្យមានចំណែកស្មើៗគ្នាគ្រប់រូប ទោះបីជាកូននោះជាកូនបង្កើតក្តី ឬកូនសុំក្តី[79]។

### ច. សិទ្ធិប្តឹងទាមទារមិតក

ជាទូទៅ ដូចយើងបានធ្វើការបញ្ជាក់នៅខាងលើថាកូនៗទាំងអស់ មិនថាកូនបង្កើត ឬកូនសុំទេ សុទ្ធតែត្រូវក្លាយជាសន្តតិជនលំដាប់ទី១។ ដូច្នេះ មានន័យថា កូនៗមានសិទ្ធិទទួលបានមិតកពីមតកជនជានិច្ច បើខ្លួនពុំត្រូវបានកាត់កាល់ ឬក្លាយជាអភ័ព្វបុគ្គលទេ។ ប៉ុន្តែបើក្នុងករណីដែលកូនណាមួយពុំទទួលបានមិតកពីមតកជន ទាំងដែលខ្លួនគ្មានកំហុសអ្វីនោះ កូននោះអាចមានសិទ្ធិប្តឹងទាមទារ ដើម្បីទទួលបានចំណែកមិតកដែលជារបស់ខ្លួន។ នៅក្នុងករណីនេះ ចំណែកមិតកត្រូវតែចែកស្មើៗគ្នា ទោះជាកូននោះជានីតិជន ឬអនីតិជន ជាកូនបង្កើត ឬកូនសុំក៏ដោយ។

---

[77] សន្តតិជនៈ ជនដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

[78] មាត្រា១១៥៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[79] មាត្រា១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## ផ្នែកទី២ ៖ សិទ្ធិរបស់កូនសុំធម្មតា

សិទ្ធិរបស់កូនសុំធម្មតា និងកូនសុំពេញលេញ គឺមានភាពស្រដៀងគ្នាបំផុត។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ សិទ្ធិរបស់កូនសុំធម្មតាហាក់មានច្រើនជាងកូនសុំពេញលេញ។ តើអ្វីដែលអាចឱ្យយើងសន្និដ្ឋានថា កូនសុំធម្មតាមានសិទ្ធិច្រើនជាងកូនសុំពេញលេញ? យើងឃើញថា កូនសុំធម្មតាមិនបានផ្តាច់ទំនាក់ទំនងញាតិពីឪពុកម្តាយបង្កើតនោះទេ ដូច្នេះកូនសុំធម្មតាអាចទទួលបានផលប្រយោជន៍ពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

### ក. សិទ្ធិប្រើប្រាស់នាមត្រកូលដែលខ្លួនពេញចិត្ត

នៅក្នុងការប្រើប្រាស់នាមត្រកូល កូនសុំធម្មតាមានសិទ្ធិក្នុងការប្រើប្រាស់នាមត្រកូលរបស់ខ្លួនដែលមាននៅមុនពេលបង្កើតសុំកូនក៏បាន ឬប្រើប្រាស់នាមត្រកូលតាមឪពុកម្តាយចិញ្ចឹមក៏បានដែរ ពោលគឺដូចគ្នាទៅនឹងការកូនសុំពេញលេញដែរ។

### ខ. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម

បើយើងក្រឡេកមើលទៅកថាខណ្ឌទី១ ចំណុចគ[80]កូនសុំពេញលេញត្រូវផ្តាច់ទំនាក់ទំនងញាតិភាពពីឪពុកម្តាយបង្កើត ដូច្នេះគេអាចរស់នៅស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមនៅក្នុងពេលដែលគេមិនទាន់ក្លាយជានីតិជន។

ប៉ុន្តែ ចំពោះកូនសុំធម្មតាវិញ គេនៅតែអាចបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត ដូច្នេះច្បាប់បានផ្តល់សិទ្ធិឲ្យគេស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

### គ. សិទ្ធិទទួលបានអាហារកាតព្វកិច្ច

កូនៗគ្រប់រូបមិនថាជាកូនបង្កើត ឬជាកូនចិញ្ចឹមនោះទេ សុទ្ធតែមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីអាណាព្យាបាលរបស់ខ្លួន។ ហេតុនេះហើយ យើងអាចទាញពន្យល់បានថា នៅពេលបង្កើតសុំកូនធម្មតា កូនសុំបានក្លាយជាកូនរបស់ឪពុកម្តាយចិញ្ចឹម ប៉ុន្តែកូននោះនៅតែជាកូនរបស់ឪពុកម្តាយបង្កើតដដែល ដូច្នេះកូនសុំនោះអាចមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីសំណាក់ឪពុកម្តាយទាំងសងខាង ពោលគឺទាំងឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម។

### ឃ. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម

យើងបានដឹងពីខាងលើហើយថា សន្តតិកម្មជាការផ្ទេរសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឲ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់។ ចំពោះកូនសុំពេញលេញ ដែលបានផ្តាច់

[80] ចំនុចគ សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងញាតិពីឪពុកម្តាយបង្កើតហើយនោះ គេអាចទទួលបានសិទ្ធិធ្វើ និងទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ។

ផ្ទុយទៅវិញ ចំពោះកូនសុំធម្មតា គឺគេទទួលបានផលប្រយោជន៍ច្រើនជាងកូនសុំពេញលេញ ត្រង់ថា គេនៅបន្តទំនាក់ទំនងញាតិជាមួយឪពុកម្តាយបង្កើត ដូច្នេះចំពោះសិទ្ធិធ្វើ និងទទួលសន្តតិកម្ម គេអាចមានសិទ្ធធ្វើ និងទទួលសន្តតិកម្មពីឪពុកម្តាយបង្កើត និងញាតិលោហិតបង្កើតផង និង ឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់គាត់ផង។

**ខ. សិទ្ធិប្តឹងទាមទារមតិក**

ចំពោះសិទ្ធិនេះ ទាំងកូនសុំពេញលេញ និងកូនសុំធម្មតាសុទ្ធតែអាចទទួលបាន ព្រោះថាសិទ្ធិនេះ កូនសុំអាចធ្វើបាន នៅពេលដែលខ្លួនពុំទទួលបានមតិកដែលជាចំណែករបស់ខ្លួន។ ដូច្នេះចំពោះកូនសុំធម្មតា គេអាចមានសិទ្ធិប្តឹងទាមទារមតិកពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង ក្នុងករណីដែលគេត្រូវបានកាត់ផ្តាច់ចេញពីមតិកដោយពុំមានហេតុផលសមស្របណាមួយ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទ «**ការសុំកូន និងសិទ្ធិរបស់កូនសុំនៅព្រះរាជាណាចក្រកម្ពុជា**» រួចមក យើងសង្កេតឃើញថា វាពិតជាមានសារៈសំខាន់ណាស់សម្រាប់និស្សិត ក៏ដូចជាប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលគួរតែយល់ដឹងពីបញ្ហានេះ។ នៅក្នុងច្បាប់ស្តីពីអាពាហ៍ និងគ្រួសារបានឱ្យនិយមន័យពាក្យថា «**ការសុំកូន**» នេះថា ជាកិច្ចសន្យា ដែលចងបុគ្គល២ (ពីរ)នាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នាដូចជាបុត្តភាពមានខាន់ស្លា[81]។

មួយវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងប្រភេទនៃការសុំកូន គឺមាន២ (ពីរ)ប្រភេទ នោះគឺការសុំកូនពេញលេញ និងការសុំកូនធម្មតា។ «**ការសុំកូនពេញលេញ**» គឺជាការសុំអនីតិជនដែលមានអាយុក្រោម៨ (ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំដោយបញ្ចប់ញាតិភាព រវាងញាតិលោហិតនៃឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ[82]។ ចំនែកឯង «**ការសុំកូនធម្មតា**» ជាការសុំកូន ដែលកូននោះអាចជាអនីតិជន ឬនីតិជន ដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការដែរ[83]។

ចំពោះការសុំកូនពេញលេញ និងការសុំកូនធម្មតា គឺច្បាប់តម្រូវឱ្យភាគីទាំងពីរនៃសុំកូនគោរពតាមលក្ខខណ្ឌមួយចំនួន ហើយលក្ខខណ្ឌទាំងនោះមានលក្ខណៈដូចនឹងលក្ខខណ្ឌក្នុងការបង្កើតកិច្ចសន្យាទូទៅដែរ គឺត្រូវបានចែកជា២ (ពីរ)ផ្នែកធំៗ គឺលក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌ ទម្រង់។ លក្ខខណ្ឌគ្រឹះ គឺជាលក្ខខណ្ឌដែលកំណត់ចំពោះភាគីឪពុកម្តាយចិញ្ចឹម និងភាគីកូនសុំផ្ទាល់តែម្តង ដែលមានដូចជា អាយុ ការមានសហព័ទ្ធ សមត្ថភាព និងស្ថានភាពគ្រួសារ។ ហើយលក្ខខណ្ឌទម្រង់វិញ ជាលក្ខខណ្ឌដែលភាគីជាអ្នកមានសិទ្ធិក្នុងការដាក់ពាក្យ ត្រូវធ្វើការដាក់ពាក្យទៅតុលាការដើម្បីសុំបង្កើតការសុំកូន។

ក្រោយពីដាក់ពាក្យសុំបង្កើតការសុំកូនរួចរាល់ហើយ បើតុលាការចេញសេចក្តីសម្រេចអនុញ្ញាតឲ្យបង្កើតការសុំកូននោះ ការសុំកូននឹងបង្កើតអានុភាពគតិយុត្តឡើង។ អានុភាពចំពោះការសុំកូនពេញលេញ គឺការបង្កើតញាតិភាពថ្មីមួយរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ដែលកូនសុំនោះនឹងក្លាយជាកូនពេញសិទ្ធិរបស់ឪពុកម្តាយចិញ្ចឹម។ មួយវិញទៀត គឺមានអានុភាពកាត់ផ្តាច់ទំនាក់

[81] មាត្រា១០៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ។

[82] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី។

[83] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី។

ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតរួមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតដែរ ដែលជាហេតុនាំឱ្យពួកគេក្លាយជាអ្នកដទៃតែម្ដង។ ចំណែកអានុភាពនៃការសុំកូនធម្មតាវិញ គឺបង្កើតញាតិភាពថ្មីរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹមដូចគ្នា ប៉ុន្តែវាមិនមានអានុភាពកាត់ផ្ដាច់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតនោះទេ ពោលគឺកូនបង្កើត និងឪពុកម្ដាយបង្កើត រួមទាំងញាតិលោហិតទាំងអស់ នៅតែអាចបន្តរហូតបាន។

នៅពេលដែលច្បាប់អនុញ្ញាតឱ្យមានការបង្កើតសុំកូន គេសួរថា តើគេអាចកាត់កាល់ការសុំកូននោះវិញបានទេ? ចម្លើយគឺពិតជាបាន ប៉ុន្តែនៅក្នុងការកាត់កាល់សុំកូននីមួយៗ គេតម្រូវឱ្យភាគីដែលមានសិទ្ធិក្នុងការកាត់កាល់បំពេញលក្ខខណ្ឌសំខាន់ៗមួយចំនួន និងត្រូវដាក់ពាក្យសុំកាត់កាល់សុំកូនដូចគ្នានឹងពេលបង្កើតសុំកូនដែរ។ ចំពោះការសុំកូនពេញលេញ ជនដែលអាចមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ទៅតុលាការបាន មានដូចជា កូនសុំ ឪពុកម្ដាយបង្កើត និងតំណាងអយ្យការ[84]។

ដោយឡែក ការកាត់កាល់សុំកូនធម្មតាវិញ មានភាពស្មុគស្មាញបន្តិច ដោយការកាត់កាល់សុំកូនធម្មតាមានចែកចេញជាពីរបែបធំៗ គឺការកាត់កាល់ដោយការព្រមព្រៀងគ្នា [85]និងការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់[86]។ ក្នុងករណីដែលគេធ្វើការកាត់កាល់ដោយការព្រមព្រៀងគ្នានោះភាគីទាំងសងខាងនៃសុំកូន សុទ្ធតែមានសិទ្ធិក្នុងការដាក់ពាក្យសុំកាត់កាល់ទៅតុលាការ ឱ្យតែបញ្ជាក់ថាវាជាការព្រមព្រៀងគ្នាក្នុងការកាត់កាល់សុំកូននោះពិតមែន ប៉ុន្តែបើភាគីកូនសុំជាអនីតិជន នោះអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ជាអ្នកដាក់បាក្យសុំជំនួសកូនសុំនោះ។ ផ្ទុយទៅវិញ បើការកាត់កាល់នោះមិនធ្វើតាមការព្រមព្រៀងគ្នាទេ មុននឹងគេអាចធ្វើការកាត់កាល់បាន គេត្រូវតែមានមូលហេតុដូចដែលច្បាប់បានកំណត់ ទើបតុលាការអាចធ្វើការសម្រេចឱ្យកាត់កាល់កូនសុំធម្មតាបាន។ មូលហេតុដែលច្បាប់បានកំណត់នោះមានដូចជា ត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត មិនច្បាស់ថាភាគីម្ខាងទៀតនៅរស់ ឬស្លាប់ក្នុងពេល១(មួយ)ឆ្នាំ ឬមានហេតុធ្ងន់ធ្ងរផ្សេងៗទៀតទេ[87]។ នៅក្នុងការកាត់កាល់សុំកូនតាមវិធីនេះ បុគ្គលដែលមានសិទ្ធិដាក់ពាក្យទៅតុលាការ ត្រូវដាក់ពាក្យបណ្ដឹងមិនមែនជាពាក្យសុំ ដូចការកាត់កាល់តាមវិធីផ្សេងៗនោះទេ ហើយទម្រង់នៃពាក្យបណ្ដឹងនោះមានភាពខុសគ្នាពីពាក្យសុំបន្តិចបន្តួចដែរ[88]។

[84] មាត្រា១០១៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[85] មាត្រា១០២៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[86] មាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[87] មាត្រា១០៣១ (ចំនុច ក ខ និងគ) នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[88] មាត្រា៦៤&៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ចំនុចចុងក្រោយគឺ សិទ្ធិរបស់កូនសុំ។ យោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ បន្ទាប់ពីការសុំកូនមានអានុភាពគតិយុត្តហើយនោះ កូនសុំត្រូវទទួលបានសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ។ ប៉ុន្តែបើយើងមើលពីសិទ្ធិរបស់កូនៗវិញ គឺមានចំនួនច្រើនដែលយើងពិបាកក្នុងការពណ៌នាឱ្យអស់ ដូច្នេះយើងក្រឡេកទៅមើលសិទ្ធិដែលសំខាន់ៗ ដែលកូនសុំអាចទទួលបាន។ សិទ្ធិដែលកូនសុំពេញលេញ និងកូនសុំធម្មតាមាន វាមិនមានលក្ខណៈខុសគ្នាទាំងស្រុងនោះទេ តែអាចនិយាយបានថាកូនសុំធម្មតាអាចទទួលបានអត្ថប្រយោជន៍បានច្រើនជាងកូនសុំពេញលេញ។ សិទ្ធិដែលកូនសុំពេញលេញអាចទទួលបានមានដូចជា សិទ្ធិទទួលដឹងពីកំណើត សិទ្ធិប្រើប្រាស់នាមត្រកូលដែលខ្លួនពេញចិត្ត សិទ្ធិស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម សិទ្ធិទទួលបានអាហារកាតព្វកិច្ច សិទ្ធិផ្ញើ និងទទួលសន្តតិកម្ម សិទ្ធិប្តឹងទាមទារមិតក។ ចំណែកឯសិទ្ធិដែលកូនសុំធម្មតាអាចទទួលបានមានដូចជា សិទ្ធិប្រើប្រាស់នាមត្រកូលដែលខ្លួនពេញចិត្ត សិទ្ធិស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត សិទ្ធិទទួលបានអាហារកាតព្វកិច្ចពីឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត សិទ្ធិផ្ញើ និងទទួលសន្តតិកម្មពីឪពុកម្តាយទាំងសងខាង សិទ្ធិប្តឹងទាមទារមិតកដូចគ្នា។

សរុបសេចក្តីមក ការបង្កើតសុំកូននៅព្រះរាជាណាចក្រកម្ពុជា មាន២ (ពីរ) ធំៗគឺ ការសុំកូនពេញលេញ និងការសុំកូនធម្មតា។ ទោះជាគេចង់បង្កើតមួយណាក៏ដោយ គេត្រូវធ្វើតាមនីតិវិធីដែលច្បាប់បានកំណត់ ទើបអាចមានអានុភាពគតិយុត្ត និងបញ្ជាក់ថាអ្នកចង់បង្កើតសុំកូនដោយគោលបំណងសុចរិត។ ការធ្វើបែបនេះ អាចធានាបានថា កុមារដែលនឹងក្លាយជាកូនសុំអាចទទួលបានផលប្រយោជន៍ដែលខ្លួនត្រូវទទួលបាន និងដើម្បីការពារសិទ្ធិកូនសុំនោះផង។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវ និងធ្វើសេចក្តីសន្និដ្ឋានជារួម លើប្រធានបទទាំងមូលរួចមក ក្នុងនាមខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាប្រជាពលរដ្ឋកម្ពុជាមួយរូប សូមផ្តល់អនុសាសន៍ខ្លះៗ ក្នុងគោលបំណងចង់ឱ្យសិស្ស-និស្សិតទាំងអស់ ព្រមទាំងប្រជាពលរដ្ឋទាំងអស់ បានយល់ដឹងបន្ថែមពីច្បាប់ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ជាពិសេសច្បាប់ស្តីពីការសុំកូនតែម្តង។ ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ គួរតែធ្វើការផ្សព្វផ្សាយច្បាប់នេះដល់ប្រជាពលរដ្ឋតាមរយៈ៖

- គួរតែបញ្ចូលច្បាប់សំខាន់ៗនានា ក្នុងកម្មវិធីសិក្សាថ្នាក់បឋមភូមិ និងទុតិយភូមិ ដើម្បីឱ្យប្អូនៗជាសិស្ស បានយល់ចាប់ពីថ្នាក់ក្រោមមក។
- ផ្សព្វផ្សាយតាមបណ្តាញសង្គម ឬតាមរយៈទូរទស្សន៍ វិទ្យុ កាសែត ជាដើម ។ល។
- បើកវគ្គបណ្តុះបណ្តាល តាមរយៈការបង្កើតជាសិក្ខាសាលា និងចែកចាយចំនេះដឹងស្តីពីការសុំកូននៅព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិរបស់កូនសុំ ដើម្បីឱ្យមហាជនទូទៅបានជ្រាប។
- ជម្រុញឱ្យមានការពន្យល់ និងបកស្រាយឱ្យបានច្បាស់លាស់ពីបញ្ហាសុំកូន។
- ស្ថាប័នដែលពាក់ព័ន្ធគួរខិតខំរកដំណោះស្រាយ ដើម្បីបញ្ឈប់ការជួញដូរកុមារ ការកេងប្រវ័ញ្ចកុមារតាមរយៈរូបភាពនៃការសុំកូននេះ។

ជាចុងក្រោយនេះ ប្រជាពលរដ្ឋទាំងអស់គ្នា គប្បីនាំគ្នាគោរពច្បាប់ដែលមានចែងក្នុងព្រះរាជាណាចក្រកម្ពុជា និងជួយការពារផលប្រយោជន៍ និងសិទ្ធិកុមារ ជៀសវាងការប្រើអំពើហិង្សា ឬទារុណកម្ម ឬបង្កើតការសុំកូនក្នុងគោលបំណងទុច្ចរិត ព្រោះកុមារគឺជាទំពាំងស្នងឬស្សីទៅថ្ងៃអនាគត។

# ឯកសារយោង

# ឯកសារយោង

## លិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ជាតិ
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
  - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
  - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
  - ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
  - ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- ច្បាប់អន្តរជាតិ
  - អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៩០ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២

## វចនានុក្រម និងសន្ទានុក្រម

- វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត
- សន្ទានុក្រមផ្នែក រដ្ឋប្បវេណី
- សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី រៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពដោយទីស្តីការគណៈរដ្ឋមន្ត្រី ឆ្នាំ២០០៧

## ផ្សេងៗ

- កម្មវិធីបង្ហាញច្បាប់នៃវិភាគទានច្បាប់ទាក់ទងនឹងប្រធានបទ «ការចិញ្ចឹមកូនតាមផ្លូវច្បាប់(សុំកូនពេញលេញ)» ដោយលោក ស៊ិន ច័ន្ទផល្គុន សមាជិកវគ្គបណ្តុះបណ្តាលពិសេសជំនាន់ទី១ នៃវិភាគទានច្បាប់
- កម្រងមេរៀននៃវិភាគទានច្បាប់ ឆ្នាំ២០១៥

# ឧបសម្ព័ន្ធ

– ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
– មនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
– ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០
– ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
– អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៩០ ដែលកម្ពុជាបានផ្តល់ច្បាប័ននៅថ្ងៃទី១៥ ខែតុ ឆ្នាំ១៩៩២